ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ

THE PROCESS OF COLLECTING TAX ON GENERAL DEPARMENT OF TAXATION OF TRANSPORTATION

**ជំនាញ គណនេយ្យ**

**រាជធានីភ្នំពេញ-ឆ្នាំ២០២៥**

PHNOM PENH-2025

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

សាកលវិទ្យាល័យ វ៉ាន់ដា

VANDA UNIVERSITY

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន របស់អគ្គនាយកដ្ឋានពន្ធដារ

THE PROCESS OF COLLECTING TAX ON GENERAL
DEPARMENT OF TAXATION OF TRANSPORTATION

គ្រូណែនាំ៖ ជន កល្យាណ

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៥

PHNOM PENH-2025

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២២**

**ប្រធានបទ៖ ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត មាស សំណាង

គ្រូណែនាំ

ជន កល្យាណ

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ែម សុខហៀក

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

ប្រធានគណៈកម្មការវាយតម្លៃ និងជានាយកមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

អនុប្រធានគណៈកម្មការវាយតម្លៃ និងជានាយករងមជ្ឈមណ្ឌលស្រាវជ្រាវ

បេក្ខបណ្ឌិត ស្រេង ផល្លា

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

សាកលវិទ្យាធិការរងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យនៅសាកលវិទ្យាល័យវ៉ាន់ដា អស់រយៈពេល ៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យជាពិសេស ក្រុមយើងខ្ញុំយល់ច្បាស់ថាជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្ដី ឯកជនក្ដី ឬអង្គការក្រៅរដ្ឋាភិបាលក្ដី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់សាកលវិទ្យាល័យវ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យនិងហិរញ្ញវត្ថុនិងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាឆ្នាំទី១រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ពីការអនុវត្តការងារធនាគារពីការចាប់ផ្ដើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្ដល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងនៅក្នុងស្ថាប័នខ្លួន ក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថាកិច្ចការងារមួយនេះ មានសារៈសំខាន់ខ្លាំងស្របពេលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្ដីពី "**ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណានិងប្រសិទ្ធភាពនៃដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន។ក្រុមយើងខ្ញុំសង្ឃឹមថាការរៀបចំសារណានេះនឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀតដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូអ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់ នូវរាល់កំហុសឆ្គងដែលកើតមានដោយអចេតនានៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពកាន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធ



**ស៊ិន សុខនី**
ID: B22/290



**តា ស្រីណុច**
ID: B22/2170



**យុត ផ្កាយ**
ID: B22/292



**ពន្លឺ សុភា**
ID: B22/519

# សេចក្ដីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃសាកលវិទ្យាល័យវ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២២ ជំនាញ គណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្ត ដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់យើងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះអ្នកគ្រូ **ជន កល្យាណ** ជាគ្រូណែនាំ ដោយបានជួយជ្រោមជ្រែងបង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និងបុគ្គលិកនៃសាកលវិទ្យាល័យវ៉ាន់ដាទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# សេចក្តីអំណះអំណាង

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រជំនាញគណនេយ្យនៃ សាកលវិទ្យាល័យ វ៉ាន់ដា ជំនាន់២២ សូមធានាអះអាងថាខ្លឹមសារ នៃកិច្ចការសារណានេះក្រោមប្រធានបទ " ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ " នេះជាស្នាដៃរបស់ក្រុមយើងខ្ញុំ ដោយគ្មានការពាក់ព័ន្ធទៅនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលទាំងមូលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃពុធ ៨កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស២៥៦៩

ថ្ងៃទី២៩ ខែតុលា ឆ្នាំ២០២៥

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន គឺជាកាតព្វកិច្ចរបស់អ្នកជាប់ពន្ធគ្រប់គ្នាដែលបានចែងនៅក្នុងច្បាប់ និងបទបញ្ញត្តិស្តីពីសារពើពន្ធ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ដូចជាអគ្គនាយកដ្ឋានពន្ធដារ បានធ្វើការផ្សព្វផ្សាយយ៉ាងច្រើនអំពីច្បាប់សារពើពន្ធនេះ តែអ្នកជាប់ពន្ធមួយចំនួន នៅតែមិនទាន់យល់ពីការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន មិនដឹងថាខ្លួនត្រូវបង់ប៉ុន្មាន បង់តាមវិធីសាស្ត្រណាខ្លះ បង់ពន្ធដើម្បីអ្វី និងខ្លះនៅតែគេចវេសមិនព្រមបង់ពន្ធ។ រីឯប្រជាជនមួយចំនួនតូចនៅតែមិនទាន់យល់ច្បាស់អំពីច្បាប់ពន្ធលើមធ្យោបាយដឹកជញ្ជូនដោយមិនដឹងថា មធ្យោបាយដឹកជញ្ជូនណាខ្លះត្រូវជាប់បង់ពន្ធ ហើយត្រូវបង់ប្រាក់ពន្ធប៉ុន្មាន។

អគ្គនាយកដ្ឋានពន្ធដារ មានតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលចំណូលសារពើពន្ធចូលជាថវិកាជាតិ។ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងដំបូងនៅឆ្នាំ១៩៥៣ ត្រូវបានលុបបំបាត់ចោលទាំងស្រុងដោយរបបប៉ុលពត នៅឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ បន្ទាប់មកនៅឆ្នាំ១៩៨០ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ និងត្រូវបានដំឡើងជាអគ្គនាយកដ្ឋានពន្ធដារ ដោយសាលាជាតិពន្ធដារ នៅឆ្នាំ២០០៨។ ក្នុងដំណើរការប្រមូលចំណូល អគ្គនាយកដ្ឋានពន្ធដារបានរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ដើម្បីជាផែនទីសម្រាប់ឆ្ពោះទៅគោលដៅប្រកបដោយជោគជ័យក្នុងនោះផងដែរ អគ្គនាយកដ្ឋានពន្ធដារបានអនុវត្តគោលនយោបាយកំណែទម្រង់រយៈពេលមធ្យមពីឆ្នាំ ២០២២ ដល់ ២០២៣ និងដើម្បីឆ្លើយទៅយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម និងយុទ្ធសាស្ត្រចតុកោណជាដំណាក់កាលរបស់រដ្ឋាភិបាលផងដែរ។ នៅក្នុងផែនការយុទ្ធសាស្ត្រនេះគឺផ្តោតទៅលើកំណែទម្រង់រួមមានកំណែទម្រង់គោលនយោបាយសារពើពន្ធ និងកំណែទម្រង់រដ្ឋបាលសារពើពន្ធ។

ដោយយោងទៅតាមការសិក្សាស្រាវជ្រាវ ឃើញថាអគ្គនាយកដ្ឋានពន្ធដារមានការខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងយុទ្ធនាការកៀរគរចំណូលពន្ធធ្វើយ៉ាងណាឱ្យគ្រប់ផែនការ ស្របតាមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់មកដោយមិនតម្លើងអត្រាពន្ធនិងបង្កើតពន្ធថ្មីហើយជាលទ្ធផលបានប្រមូលលើសការរំពឹងទុកទៅទៀត។ សមិទ្ធផលនេះយើងអាចចាត់ទុកជាប្រមុខដឹងនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលមានភាពឈ្លាសវៃក្នុងយុទ្ធនាការបង់ពន្ធប្រកបដោយភាពប្រុងប្រយ័ត្នខ្ពស់។ ថវិកាដែលបានពីការបង់ពន្ធនេះនឹងត្រូវយកទៅចំណាយទៅលើការសាងសង់ ជួសជុលផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ និងបើកប្រាក់បៀវត្សដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលជាអ្នកទទួលបន្ទុកផ្តល់សេវារដ្ឋបាល ការពារសន្តិសុខសណ្តាប់ធ្នាប់ ការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេសកម្ពុជា។ យើងសង្កេតឃើញថាសព្វថ្ងៃនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងអគ្គនាយកដ្ឋានពន្ធដារ បានយកចិត្តទុកដាក់ណែនាំផ្សព្វផ្សាយបន្ថែមទៀតឱ្យកាន់តែទូលំទូលាយ និងយល់ច្បាស់អំពីការបង់ពន្ធជូនទៅដល់ប្រជាពលរដ្ឋ។ ជាក់ស្តែងដោយមានការណែនាំ តាមប្រព័ន្ធអេឡិចត្រូនិច ហើយក៏មានការបង្ហាត់បង្រៀនដោយផ្ទាល់ផងដែរ។យ៉ាងណាមិញយើងក៏សង្កេតឃើញថាប្រជាពលរដ្ឋពួកគាត់ក៏មានការយល់ដឹង និងបានចូលរួមបង់ពន្ធកាន់តែច្រើនជាងមុន។ ហេតុដូច្នេះពួកយើងក៏សង្ឃឹមថា ការខិតខំប្រឹងប្រែងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងអគ្គនាយកដ្ឋានពន្ធដារនិងមានការរីកចម្រើនទៅមុខជាលំដាប់។

# មាតិកា

ទំព័រ

អារម្ភកថា ........ i
រចនាសម្ព័ន្ធ ........ ii
សេចក្ដីថ្លែងអំណរគុណ ........ iii
សេចក្ដីអំណះអំណាង ........ iv
សេចក្ដីសង្ខេបនៃការស្រាវជ្រាវ ........ v
មាតិកា ........ vi

## ជំពូកទី១
## សេចក្ដីផ្ដើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
១.៣. គោលបំណងនៃការស្រាវជ្រាវ ........ ២
១.៤. ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២
១.៤.១. ទំហំ ដែនកំណត់ ........ ២
១.៤.២. វិសាលភាព ........ ៣
១.៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ៣
១.៦. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

## ជំពូកទី២
## លក្ខណៈទូទៅនៃដំណើរការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ

២.១ លក្ខណៈទូទៅនៃដំណើរការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ៥
២.១.១ និយមន័យពន្ធ ........ ៥
២.១.២ ប្រវត្តិពន្ធ ........ ៥
២.១.៣ ទ្រឹស្ដីនៃពន្ធ ........ ៦
២.១.៤ ប្រភេទពន្ធ ........ ៦
២.២ នីតិវិធីនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន ........ ៧
២.២.១ និយមន័យនីតិ ........ ៧
២.២.២ ទ្រឹស្ដីនីតិ ........ ៧
២.២.៣ និយមន័យពន្ធលើមធ្យោបាយដឹកជញ្ជូន ........ ៨
២.៣ អត្ថប្រយោជន៍នៃចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូនចំពោះប្រទេសជាតិ ........ ៨
២.៣.១ និយមន័យអត្ថប្រយោជន៍ ........ ៨
២.៣.២ និយមន័យមធ្យោបាយដឹកជញ្ជូន ........ ៨

## ជំពូកទី៣
## លទ្ធផលនៃការសិក្សាស្រាវជ្រាវ

៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ........ ៩
៣.១.១ ប្រវត្តិសង្ខេបនៃអគ្គនាយកដ្ឋានពន្ធដារ ........ ៩
៣.១.២ ទស្សនវិស័យ បេសកកម្ម គុណតម្លៃ របស់អគ្គនាយកដ្ឋានពន្ធដារ ........ ១០
៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី នឹងភារកិច្ច ........ ១១
៣.២ ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន ........ ១៩
៣.២.១ នីតិវិធី ........ ១៩
៣.២.២ ការគណនាប្រាក់ពន្ធត្រូវបង់ ........ ២៥
៣.២.៣ ទីកន្លែងបង់ពន្ធ និងការបរិច្ឆេទ ........ ៣០
៣.២.៤ ការផាកពិន័យលើការខកខានមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន ........ ៣៤
៣.៣ អត្ថប្រយោជន៍នៃចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូន ចំពោះប្រទេសជាតិ ........ ៣៤

## ជំពូកទី៤
## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង ........ ៣៩
៤.២ ការវិភាគលើចំណុចខ្សោយ ........ ៣៩

## ជំពូកទី៥
## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

៥.១ សេចក្ដីសន្និដ្ឋាន ........ ៤១
៥.២ ការផ្ដល់អនុសាសន៍ ........ ៤២
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

បន្ទាប់ពីប្រវត្តិសាស្រ្តដ៏ខ្មៅងងឹតនៃប្រទេសកម្ពុជា បានបញ្ចប់ទៅជាងបួនទស្សវត្សរ៍មកនេះ ប្រទេសកម្ពុជាបានបោះជំហ៊ានយ៉ាងសន្សឹមៗទៅរកអនាគតដ៏ត្រចះត្រចង់ បើយើងសង្កេតឱ្យបានជាក់លាក់ទៅប្រទេសកម្ពុជាបានផ្លាស់ប្តូរយ៉ាងច្រើនពីសេដ្ឋកិច្ចបែបផែនការ មកជាសេដ្ឋកិច្ចទីផ្សារសេរី ពីរដ្ឋមួយដែលគ្រប់គ្រងដោយឯករាជ្យបក្សប្តូរទៅជាពហុបក្ស និងមានអភិបាលកិច្ចល្អណះប្រជាធិបតេយ្យសេរី ពីប្រទេសមួយមានសង្គ្រាមនិងវិបត្តិនយោបាយមកជាប្រទេសមួយប្រកបដោយសុខសន្តិភាពពេញលេញនិងប្រកបដោយចីរភាព។ សមិទ្ធិផលរយៈពេលពីរទស្សវត្សរ៍ក្រោយនេះ ប្រទេសកម្ពុជាបានរីកចម្រើនយ៉ាងសន្ធឹកសន្ធាប់គួរឱ្យកត់សម្គាល់ ការរីកចម្រើនទាំងអស់នេះមិនមែនកើតឡើងដោយឯកឯងទេ វាគឺជាលទ្ធផលនៃការគិតគូរទុកជាមុនដោយដាក់ចេញនូវយុទ្ធសាស្រ្ត និងគោលនយោបាយផ្សេងៗ ព្រមជាមួយការប្រឹងប្រែងយ៉ាងស្វិតស្វាញពីសំណាក់រាជរដ្ឋាភិបាលនិងមន្រ្តីជាច្រើនរូប។

ទន្ទឹមនឹងនេះទៀតសោធប្រទេសកម្ពុជាក៏បានបង្កើតប្រព័ន្ធច្បាប់ពន្ធជាច្រើនសម្រាប់ទុកអនុវត្ត គឺក្នុងគោលបំណងប្រមូលពន្ធពីប្រជាពលរដ្ឋដើម្បីលើកស្ទួយដល់សេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន ម្យ៉ាងវិញទៀតយើងឃើញថាប្រព័ន្ធពន្ធដារនៅកម្ពុជា ក៏មានការប្រែប្រួលទៅតាមសម័យកាលផ្សេងៗគ្នាដែរ។ តួយ៉ាងដូចជានៅឆ្នាំ២០២០ គោលនយោបាយសារពើពន្ធត្រូវបានបន្ធូរបន្ថយ ដើម្បីគាំទ្រដល់វិស័យសុខាភិបាលសាធារណៈ អន្តរាគមន៍ផ្នែកសង្គមកិច្ច និងអាជីវកម្មដែលរងផលប៉ះពាល់ដោយសារជំងឺ កូវីត១៩ ។ ក៏ប៉ុន្តែមកដល់ឆ្នាំ២០២១ វិញសេដ្ឋកិច្ចកម្ពុជាបានងើបឡើងយ៉ាងឆាប់រហ័សជាងអ្វីដែលបានរំពឹងទុកដែលជាហេតុធ្វើឱ្យអគ្គនាយកដ្ឋានពន្ធដារបានអនុវត្តការប្រមូលពន្ធចំពោះប្រភេទពន្ធមួយចំនួនដូចជា ពន្ធលើប្រាក់ចំណូល អាករលើតម្លៃបន្ថែម ពន្ធដីធ្លីមិនបានប្រើប្រាស់ ពន្ធប្រថាប់ត្រា ពន្ធប៉ាតង់ ពន្ធកាត់ទុកទូទៅ ពន្ធអចលនទ្រព្យ ពន្ធអប្បបរមា ពន្ធលើឈ្នួលផ្ទះនិងដី អាករពិសេសលើទំនិញនិងសេវាមួយចំនួន អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ ពន្ធលើប្រាក់បៀវត្ស និងពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានយន្តគ្រប់ប្រភេទ ។

បើយើងក្រឡេកទៅមើលអគ្គនាយកដ្ឋានពន្ធដារបានបង្កើតសាខាពន្ធដារគ្រប់ខេត្ត-ខណ្ឌ ទូទាំងប្រទេសនិងបានផ្តល់សេវាដល់អ្នកជាប់ពន្ធ អាករ និងមានការកែប្រែទម្រង់ប្រព័ន្ធពន្ធដារមួយចំនួនទៀតផងដែរ។ ប្រជាពលរដ្ឋយើងហាក់មានភាពយល់ដឹងច្រើនពីការប្រមូលពន្ធគឺ តាមរយៈសេវាសារធារណៈ ឬហេដ្ឋារចនាសម្ព័ន្ធដែលពួកគេប្រើប្រាស់ជារៀងរាល់ថ្ងៃដូចជា ការសាងសង់ ជួសជុលស្ពាន ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ និងការបើកប្រាក់ខែជូនដល់មន្រ្តីរាជការ កងទ័ព គ្រូបង្រៀននិងគ្រូពេទ្យ គឺរដ្ឋាភិបាលត្រូវការចំណាយថវិកាយ៉ាងច្រើន ហើយប្រភពចំណូលដ៏ធំបំផុតនៃថវិកានោះគឺបានមកពីការប្រមូលពន្ធគ្រប់ប្រភេទពីអ្នកជាប់ពន្ធ។ រាល់ការប្រមូលពន្ធនៅក្នុងប្រទេសកម្ពុជាយើង គឺជាផ្នែកមួយដ៏មានសារៈសំខាន់បំផុត ដូច្នេះហើយទើបក្រុមរបស់យើងខ្ញុំលើកយកមកនិយាយ និងពិភាក្សាគ្នាសម្រេចថាជ្រើសរើសយកប្រធានបទ មួយនេះដែលស្តីអំពី **«ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ»** យកមកសិក្សា

ស្រាវជ្រាវ និងរៀបចំជារបាយការណ៍ដើម្បីជាគន្លឹះនៃការចែករំលែកចំណេះដឹង និងស្វែងយល់ បន្ថែមទៀត ទៅដល់អ្នកដែលប្រើប្រាស់ទៅលើយានយន្តគ្រប់ប្រភេទក្នុងការបង់ពន្ធឱ្យកាន់តែច្បាស់ជាងនេះទៅទៀត។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះយើងឃើញថា ប្រទេសកម្ពុជាយើងគឺជាប្រទេសដែលកំពុងអភិវឌ្ឍ ហើយដើម្បីឱ្យប្រទេសជាតិយើងមានការរីកលូតលាស់ទៅមុខបានយ៉ាងឆាប់រហ័ស យើងគប្បីមានការជួយជ្រោមជ្រែងពីមជ្ឈដ្ឋានជុំវិញ ជាពិសេសគឺប្រជាជនតែម្តង។ ដូច្នេះហើយទើបប្រទេសយើងបង្កើតឱ្យមានការប្រមូលពន្ធផ្សេងៗ ដើម្បីយកថវិកាទាំងនោះយកមកជួយដោះស្រាយចំណាយផ្សេងៗរបស់រដ្ឋ ជាពិសេសគឺការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន ដើម្បីងាយស្រួលក្នុងការបកស្រាយប្រធានបទខាងលើឱ្យបានក្បោះក្បាយនិងត្រឹមត្រូវ ក្រុមយើងខ្ញុំមានសំនួរមួយចំនួនដូចខាងក្រោម៖

១.តើអគ្គនាយកដ្ឋានពន្ធដារមាននីតិវិធីដូចម្តេចខ្លះ ដើម្បីប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន?

២.តើចំណូលដែលទទួលបានពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន បានផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់ប្រទេសជាតិ?

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

- ដើម្បីយល់ដឹងពីប្រសិទ្ធភាពនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន
- យល់ដឹងអំពីដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន
- យល់ដឹងអំពីគោលនយោបាយ បេសកកម្ម និងទស្សនវិស័យរបស់អគ្គនាយកដ្ឋានពន្ធដារ
- យល់ដឹងអំពីប្រវត្តិនៃអគ្គនាយកដ្ឋានពន្ធដារ
- យល់ដឹងអំពីវិធីសាស្ត្រនៃការប្រមូលនិងការបង់ពន្ធ
- យល់ដឹងអំពីការវិភាគលើចំណុចខ្លាំង និងការវិភាគលើចំណុចខ្សោយ

## ១.៤. ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១. ទំហំ ដែនកំណត់

ដើម្បីឱ្យការសិក្សាស្រាវជ្រាវលើប្រធានបទ "**ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ**" បានសម្រេចដល់គោលដៅទៅតាមពេលវេលាដែលបានកំណត់ ក្រុមយើងខ្ញុំបានកំណត់នូវទំហំ និងដែនកំណត់នៃការស្រាវជ្រាវរបស់ខ្លួន គឺកំណត់ ធ្វើការសិក្សាបកស្រាយផ្តោតទៅលើតែ "ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ និងច្បាប់មួយចំនួនដែលទាក់ទងនឹងពន្ធនេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។ អគ្គនាយកដ្ឋានពន្ធដារមានទីតាំងនៅគ្រប់ក្រុង ខេត្ត ខណ្ឌ ទូទាំងប្រទេសកម្ពុជា ហើយទីតាំងនៅរាជធានីភ្នំពេញគឺ នៅអគារកែងមហាវិថីសហព័ន្ធរុស្សី(១១០) និងម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

### ១.៤.២. វិសាលភាព

ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ ១៩៥៣មកម្ល៉េះ ប៉ុន្តែក្រុមយើងខ្ញុំសូមលើកយកតែ ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន នៅចន្លោះឆ្នាំ២០២២-២០២៣តែប៉ុណ្ណោះ។

## ១.៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

សម្រាប់សំណួរទី១ ការជ្រើសរើសយកវិធីសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ គឺតាមបែបគុណវិស័យ (Qualitative Research) ដោយផ្តោតចម្បងទៅលើទិន្នន័យ និងឯកសារដែលបានមកពីវេបសាយអគ្គនាយកដ្ឋានពន្ធដារដែលពាក់ព័ន្ធទៅនឹងប្រធានបទ ដើម្បីយកមកវិភាគនិងសិក្សាស្រាវជ្រាវក្នុងគោលបំណងបញ្ជាក់ អំពីប្រសិទ្ធភាពនៃដំណើរការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ។

សម្រាប់សំណួរទី២ ការជ្រើសរើសយកវិធីសាស្ត្រសម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវ គឺតាមបែបគុណវិស័យ (Qualitative Research) ដោយផ្តោតសំខាន់ទៅលើទិន្នន័យ និងឯកសារដែលបានមកពីវេបសាយរបស់អគ្គនាយកដ្ឋានពន្ធដារ កិច្ចការស្រាវជ្រាវរបស់សិស្សច្បង និងការណែនាំពីអ្នកគ្រូដឹកនាំការស្រាវជ្រាវ។

## ១.៦. សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះធ្វើឡើងគឺមានសារៈសំខាន់ចង់ឱ្យប្រជាជនទាំងអស់បាន សិក្សាស្វែងយល់ឱ្យកាន់តែច្បាស់អំពី ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ។ ដែលមានអត្ថប្រយោជន៍ជាច្រើនដូចជា៖

- **ចំពោះអ្នកស្រាវជ្រាវ** (Researchers):
  - មានទិន្នន័យពិតប្រាកដអំពីស្ថានភាពនៃការធ្វើដំណើរ និងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូន។
  - ជាទិន្នន័យសម្រាប់ការស្រាវជ្រាវអភិវឌ្ឍន៍នគរូបនីយកម្ម ការធ្វើផែនទីចរាចរណ៍ និងបញ្ហាពាក់ព័ន្ធបរិស្ថាន។
  - ជួយឱ្យអ្នកស្រាវជ្រាវវាយតម្លៃអំពីគោលនយោបាយពន្ធ និងផលប៉ះពាល់របស់វា។
- **ចំពោះសង្គមជាតិ** (Society):
  - ជួយឱ្យមានផ្លូវល្អ ការដឹកជញ្ជូនមានសុវត្ថិភាព និងងាយស្រួល។
  - បង្កើតការស្មើភាពនៃការប្រើប្រាស់ធនធានសាធារណៈ (អ្នកប្រើមធ្យោបាយដឹកជញ្ជូនត្រូវចូលរួមចំណូលរដ្ឋ)។
  - ជួយបង្កើតការយល់ដឹងអំពីការទទួលខុសត្រូវក្នុងសង្គម និងការចូលរួមបង់ពន្ធដើម្បីអភិវឌ្ឍជាតិ។
- **ចំពោះស្ថាប័ន** (Institutions):
  - ជាប្រភពប្រាក់ចំណូលសម្រាប់រដ្ឋក្នុងការផ្តល់សេវាសាធារណៈ (ដូចជា ការជួសជុលផ្លូវ ការរក្សាសុវត្ថិភាពចរាចរណ៍)។
  - ជួយក្នុងការត្រួតពិនិត្យបរិមាណ និងសភាពនៃមធ្យោបាយដឹកជញ្ជូននៅប្រទេស។
  - ជាជំហានសំខាន់ក្នុងការគ្រប់គ្រងប្រព័ន្ធចរាចរណ៍ឱ្យមានប្រសិទ្ធភាព និងបន្ថយអត្រាធ្វើបាបបរិស្ថាន។

## ១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវត្រូវបានបែងចែកជា៥ជំពូកមានដូចខាងក្រោម៖

**ជំពូកទី១៖ សេចក្តីផ្តើម** ជំពូកនេះបានបង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។

**ជំពូកទី២៖ រំលឹកទ្រឹស្តី** ជំពូកនេះបង្ហាញពីនិយមន័យប្រវត្តិ និងទ្រឹស្តីដែលពាក់ព័ន្ធជាមួយដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន។

**ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ** ជំពូកនេះបានលើកឡើងអំពីដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ និងអត្ថប្រយោជន៍នៃចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទចំពោះប្រទេសជាតិ។

**ជំពូកទី៤៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ** ជំពូកនេះបានលើកឡើងពីការវិភាគទៅលើផលវិជ្ជមាននិងផលអវិជ្ជមាននៃដំណើរការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** ជំពូកនេះបានធ្វើការសន្និដ្ឋានដោយសង្ខេបទៅលើគ្រប់ចំណុចដែលបានវិភាគ និងការផ្តល់យោបល់ជាអនុសាសន៍ ទៅលើគ្រប់ចំណុចដែលត្រូវកែលម្អ។

# ជំពូកទី២

# លក្ខណៈទូទៅនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន របស់អគ្គនាយកដ្ឋានពន្ធដារ

## ២.១ លក្ខណៈទូទៅនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន

### ២.១.១ និយមន័យពន្ធ

**ពន្ធ**(Tax)

- គឺជាកាតព្វកិច្ចបង់ជាប្រាក់ ឬវត្ថុរបស់អ្នកជាប់ពន្ធទៅរដ្ឋាភិបាល ហើយអ្នកជាប់ពន្ធទាំងនោះទទួលតម្លៃតបស្នងពីរដ្ឋាភិបាលវិញតាមរយៈទំនិញ និងសេវាសាធារណៈ។
- គឺជាបន្ទុករបស់ប្រជាពលរដ្ឋបង់ចូលថវិកាជាតិ។ ប្រជាពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។
- ជាឧបករណ៍របស់រដ្ឋាភិបាលដែលបានបង្កើតឡើងដើម្បីកៀរគរចំណូលចូលថវិកាជាតិសម្រាប់ចំណាយសាធារណៈ។
- សំដៅដល់ ពន្ធអាករ(ពន្ធផ្ទាល់ និងពន្ធប្រយោល)[1]។

**ពន្ធ** ពន្ធអាករគឺជា កាតព្វកិច្ចរបស់រូបវន្តបុគ្គល និងនីតិបុគ្គលទាំងអស់ដែលមានចែង ក្នុងក្រិតច្បាប់ត្រូវតែចូលរួមបង់វិភាគទានជូនរដ្ឋ ក្រោមរូបភាពរួមភាពជាការប្រមូលចំណូលជាតិដើម្បីឱ្យរដ្ឋាភិបាលធ្វើការបែងចែកចំណូលឡើងវិញសម្រាប់ជាប្រយោជន៍ដល់សង្គមជាតិទាំងមូល មានន័យថារដ្ឋមិនផ្តល់សេវាកម្មទៅឱ្យ អ្នកបង់ពន្ធទាំងនោះដោយផ្ទាល់វិញឡើយ ហើយអ្នកមានចំណូលតិចបង់ពន្ធតិច អ្នកមានចំណូលច្រើនបង់ពន្ធច្រើន[2]។

### ២.១.២ ប្រវត្តិពន្ធ

ពន្ធមានប្រវត្តិតាំងពី ៣០០០ ឆ្នាំមុនគ្រឹស្តសករាជទៅទៀតដែលដំបូងនោះវាត្រូវបានគេរកឃើញនៅក្នុងប្រទេសអេស៊ីបដែលមានឈ្មោះជាអក្សរឡាតាំងថា TAX ។ វាសមហេតុផល ដែលប្រជាពលរដ្ឋត្រូវបង់ពន្ធ ហេតុដូច្នេះហើយបានជាចំណេរកាលក្រោយមក ប្រទេសជាច្រើននៅទូទាំងសកលលោកបានប្រើប្រាស់ប្រព័ន្ធប្រមូលប្រាក់ពីប្រជារាស្ត្រនេះ ទៅអោយអ្នកគ្រប់គ្រងប្រទេស។

រដ្ឋខ្មែរបានចាប់កំណើតតាំងពីសតវត្សទី១នៃគ្រឹស្តសករាជមកម្ល៉េះពេលគឺ សម័យកាលហ្វូណនតាមប្រវត្តិសាស្ត្របន្តពីហ្វូណនមានសម័យកាលជាច្រើនទៀតជាអាទិ៍ ចេនឡាអង្គរលង្វែកឧត្តុង និងចតុមុខ។ ការកំណត់ សម័យកាលទាំងនេះធ្វើឡើងដោយផ្អែកលើការផ្លាស់ប្តូររាជធានី ពីកន្លែងមួយទៅកន្លែងមួយដែលមានរយៈពេលប្រមាណជាង ១,៥០០ ឆ្នាំ។ នៅក្នុងសម័យកាលទាំងនេះ យើងសង្កេតឃើញថា ព្រះរាជាបានប្រមូលពន្ធពីប្រជារាស្ត្រ ដោយសារព្រះអង្គបានប្រទានដីធ្លីដល់ប្រជារាស្ត្រ ដើម្បីប្រកបអាជីវកម្ម ឬកសិកម្មជាដើម។ នៅឆ្នាំ១៨៦៣ ប្រទេសបារាំងបានចូលមកធ្វើជាអាណាព្យាបាលខ្មែរ ហើយក្រោយមកបានប្រែក្លាយប្រទេសកម្ពុជាទៅ ជាទឹកដីអាណានិគមរបស់ខ្លួននាឆ្នាំ១៨៨៤ បារាំងបាននាំយកច្បាប់ និង

[1] វិទ្យាស្ថានវ៉ាន់ដា.(២០២២). ច្បាប់ពន្ធដារកម្ពុជាៈ បោះពុម្ពលើកទី៣ ទំព័រទី២ ១៨៨ទំព័រ. ភ្នំពេញ។

[2] Facebook Page. Inspired Economy. (2020, May 02). *តើពន្ធជាអ្វី?* Retrieved March, 02 2025 from https://www.facebook.com/SREYNITECO/posts/pfbid0LYuADZio9aogi3ojerR5vnWaGRPSRgJrYrEjYrAGEdRiq1a5eUoPymbpFxDknX9fl?rdid=4cwLXJoddgLRrA3x#

ការគ្រប់គ្រង រដ្ឋបាលមកអនុវត្តនៅក្នុងប្រទេសកម្ពុជា ជាពិសេសវិស័យសារពើពន្ធ។ ក្រោយពេលដែលទទួលបានឯករាជ្យពីអាណានិគមនិយមបារាំងនាថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កម្ពុជាមានភាពពិបាកក្នុងការវិលត្រឡប់ទៅរកការអនុវត្តច្បាប់ខ្មែរបុរាណវិញពោល គឺកម្ពុជាបានក្លាយជាប្រទេសនៃគ្រួសារប្រព័ន្ធច្បាប់រ៉ូម៉ាំង អាល្លឺម៉ង់រួចទៅហើយ។ ច្បាប់ពន្ធដារកម្ពុជា គឺជាច្បាប់ពន្ធដារដែលមានច្បាប់ ឫសគល់ចេញមកពីច្បាប់បារាំង។ បច្ចុប្បន្ននេះ កម្ពុជាមានច្បាប់ពន្ធដារបែបទំនើប និងរីកចម្រើនជួនល្មមជាអាទិ៍ ច្បាប់ស្ដីពីសារពើពន្ធ ត្រូវបានបង្កើតឡើងនាឆ្នាំ១៩៩៧ និងបទប្បញ្ញត្តិផ្សេងៗទៀត ដែលបានរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការរៀបចំបែបនេះធ្វើឡើងដើម្បីឆ្លើយតបទៅនឹងមាត្រា៥៧ នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដែលចែងថាការយកពន្ធនឹងអាចធ្វើទៅបានលុះត្រាតែមានច្បាប់អនុញ្ញាត។ ជាការពិតយើងសង្កេតឃើញរដ្ឋបានសាងច្បាប់ និងលិខិតបទដ្ឋានជាច្រើនដើម្បីធ្វើឱ្យការប្រមូលពន្ធ ពីប្រជាពលរដ្ឋមានលក្ខណៈនីត្យានុកូល[3]។

**២.១.៣ តួនាទីនៃពន្ធ**

ពន្ធមានលក្ខណៈបង្ខំ ហើយមិនសងឱ្យវិញផ្ទាល់ឡើយ។ ប៉ុន្តែនិងសងវិញជាលក្ខណៈរូបភាពប្រយោល ទៅតាមគោលនយោបាយរដ្ឋាភិបាលប្រទេសនីមួយៗ។ គ្រប់អង្គភាពអាជីវកម្ម ផលិតកម្ម សេវាកម្ម ដែលចំណុះឱ្យគ្រប់សមាសភាពសេដ្ឋកិច្ច ត្រូវមានកាតព្វកិច្ច និងទំនួលខុសត្រូវ ចំពោះមុខច្បាប់រដ្ឋ ក្នុងការអនុវត្តឱ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងដែលបានកំណត់ និងមានសិទ្ធស្មើគ្នាៗគ្នាក្នុងការទទួលយកមកវិញនូវផលប្រយោជន៍ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌និងត្រូវបានរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលមកវិញតាមរយៈគោលនយោបាយដែលមានចែងក្នុងច្បាប់។ ពន្ធបានធ្វើឱ្យមានការផ្លាស់ប្តូរកម្មសិទ្ធនៃប្រភពចំណូលដែលបានប្រមូល ។ ការផ្លាស់ប្តូរនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបានស្តែងឡើងការឯកភាពគ្នា អំពីគោលចរិតផលប្រយោជន៍របស់រដ្ឋជាមួយនិងផលប្រយោជន៍របស់ក្រុមហ៊ុនអាជីវកម្ម សេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងយឿនសេដ្ឋកិច្ចទីផ្សារ ដែលមានសមាសភាពសេដ្ឋកិច្ចច្រើន គោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចាំបាច់ ជាទូទៅពន្ធត្រូវបានចាត់ទុកជាឧបករណ៍ហិរញ្ញវត្ថុមួយយ៉ាងមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ[4]។

**២.១.៤ ប្រភេទពន្ធ**

ពន្ធគឺជាចំណូលចរន្តដ៏សំខាន់របស់រដ្ឋសម្រាប់ធ្វើការទ្រទ្រង់នូវដំណើរការនៃវិស័យសាធារណៈផ្សេងៗ ហើយប្រទេសកម្ពុជាបច្ចុប្បន្នបានកំណត់នូវពន្ធមានចំនួន ១៦ ប្រភេទ ដែលតម្រូវឱ្យប្រជាពលរដ្ឋ ឬអ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការបង់ពន្ធជូនរដ្ឋ។

១.ពន្ធលើប្រាក់ចំណូល

២.ពន្ធលើប្រាក់បៀវត្ស

៣.អាករលើតម្លៃបន្ថែម

---

[3] ហូរ ចន្ទា: (2024). ប្រធានបទ៖ *ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានដារ*. សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ. វិទ្យាស្ថានវ៉ាន់ដា. ភ្នំពេញ. ប្រទេសកម្ពុជា

[4] វ៉ែន ឈុនហួត. (2021). *សញ្ញាណទូទៅនៃពន្ធដា*. សាកលវិទ្យាល័យឯកទេសនៃកម្ពុជា Retrieved March 02 2025 from https://chandaracitc.weebly.com/uploads/1/3/0/1/13016555/taxation.pdf

៤.ពន្ធអប្បបរមា

៥.ពន្ធកាត់ទុកទូទៅ

៦.អាករពិសេស

៧.ពន្ធលើចំណេញមូលធន

៨.អាករសម្រាប់បំភ្លឺសាធារណៈ

៩.អាករលើការស្នាក់នៅ

១០.ពន្ធលើលើមធ្យោបាយដឹកជញ្ជូន

១១.ពន្ធប៉ាតង់

១២.ពន្ធលើដីធ្លីមិនបានប្រើប្រាស់

១៣.ពន្ធប្រថាប់ត្រា

១៤.ពន្ធលើផ្ទាំងផ្សព្វផ្សាយ

១៥.ពន្ធលើអចលនទ្រព្យ

១៦.ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ[5]។

## ២.២ នីតិវិធីនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន

### ២.២.១ និយមន័យនីតិ

- នីតិ គឺជាបណ្តុំវិធានគតិយុត្តដែលមានចំណាងសិទ្ធិនិងកាតព្វកិច្ចមានអនុភាពឱ្យចាប់បង្ខំមានលក្ខណៈទូទៅមិនចំពោះនិងមានគោលដៅរៀបចំសណ្តាប់ធ្នាប់ឱ្យមានរបៀបរៀបរយក្នុងសង្គម។
- នីតិ គឺជាវិធានទាំងឡាយណាដែលគ្រប់គ្រងការរស់នៅក្នុងសង្គមហើយត្រូវតែអនុវត្តន៍ និងផ្តន្ទាទោសដោយអំណាចរដ្ឋ។
- នីតិ ជាបណ្តុំវិធានសម្រាប់គ្រប់គ្រងសង្គមនិងដឹកនាំប្រទេសផងដែរ។
- ការប្រមូលពន្ធ សំដៅទៅលើការប្រមូលចំណូលដែលរដ្ឋាភិបាលបានដកហូតពីពលរដ្ឋ។
- ការប្រមូលពន្ធ គឺជាមធ្យោបាយដែលរដ្ឋាភិបាលប្រមូលយកមកដើម្បីប្រើប្រាស់ធ្វើជាប្រយោជន៍ដល់សង្គមជាតិទាំងមូល។
- ការប្រមូលពន្ធ គឺដើម្បីឱ្យពលរដ្ឋបានបំពេញកាតព្វកិច្ចជាពលរដ្ឋល្អ និងមានទំនួលខុសត្រូវចំពោះប្រទេសជាតិ។

### ២.២.២ ទ្រឹស្តីនីតិ

លោក K.Mark និង F.Engels បានកំណត់និយមន័យនីតិថា៖

- នីតិ ត្រូវបានចាត់ទុកដូចជាឆន្ទៈដែលកសាងឡើងនៅក្នុងច្បាប់ពាក្យដែលបានវិភាគនេះត្រូវបានគេប្រើប្រាស់នៅក្នុងន័យទូលំទូលាយដែលនៅក្នុងនោះ មានលិខិតបទដ្ឋាន និងសាលក្រមគំរូ ( Judicial Precedent ) និងទំនៀមទម្លាប់។
- នីតិ ត្រូវមានមូលដ្ឋានកំណត់ជាក់លាក់ ក្របខ័ណ្ឌរបស់នីតិត្រូវតែធ្វើទៅតាមទម្រង់យ៉ាងប្រាកដត្រឹមត្រូវ។

[5] វិទ្យាស្ថានវ៉ាន់ដា.(២០២២). *ច្បាប់ពន្ធដារកម្ពុជា*. បោះពុម្ពលើកទី៣. ទំព័រទី៤. ១៨៨ទំព័រ. ភ្នំពេញ។

- នីតិ ត្រូវបានទទួលស្គាល់លុះត្រាតែនីតិនេះឯងកសាងឡើងទៅក្នុងច្បាប់បើនៅក្រៅច្បាប់វាក៏មិនអាចកើតមានដែរ។
- នីតិ វាខុសពីប្រពៃណី ទំនៀមទម្លាប់ សីលធម៌ និងសាសនា ព្រោះនីតិត្រូវបានជានាការអនុវត្តដោយអំណាចរដ្ឋ។
- នីតិ កើតឡើងពីឆន្ទៈរួម ដែលចង់រស់នៅដោយសុខសាន្ត មានវឌ្ឍនភាព មានសិទ្ធិសេរីភាព[6]។

**២.២.៣ និយមន័យពន្ធលើមធ្យោបាយដឹកជញ្ជូន**

ពន្ធលើមធ្យោបាយដឹកជញ្ជូន សំដៅដល់ពន្ធប្រចាំឆ្នាំលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទរួមមាន រថយន្តទេសចរណ៍ រថយន្តដឹកទំនិញ រថយន្តដឹកអ្នកដំណើរ រ៉ឺម៉កសណ្តោងឬ ជលយានយន្ត(លើសពី ១៥0cc) ទាំងផ្លូវទន្លេរ និងសមុទ្រ[7]។

ពន្ធលើមធ្យោបាយដឹកជញ្ជូននឹងយានជំនិះ គឺជាពន្ធដែលត្រូវបង់ដោយបុគ្គលឬអង្គភាពដែលប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ឬយានជំនិះសម្រាប់ការដឹកជញ្ជូនទំនិញ ឬមនុស្ស។ ពន្ធនេះអាចគ្របដណ្តប់លើការប្រើប្រាស់យានយន្តទាំងអស់ដូចជា រថយន្ត, រថភ្លើង, យន្តហោះ, សហព័ន្ធ ឬម៉ូតូ ដែលមានប្រើប្រាស់ក្នុងការដឹកជញ្ជូននានា។ បូករួមទៅនឹងការបង់ពន្ធផ្សេងៗដែលត្រូវបានកំណត់ឱ្យមានការបញ្ចូលរាល់នៃការប្រើប្រាស់មធ្យោបាយដឹកជញ្ជូន ឬការផ្គត់ផ្គង់សេវាកម្មដល់សាធារណៈ។

## ២.៣ អត្ថប្រយោជន៍នៃចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូន ចំពោះប្រទេសជាតិ

**២.៣.១ និយមន័យអត្ថប្រយោជន៍**

អត្ថប្រយោជន៍ គឺជាអំណាចនៃទំនិញឬសេវាកម្មដើម្បីបំពេញតម្រូវការនិងចំណង់ចំណូលចិត្តរបស់អតិថិជន[8]។

អត្ថប្រយោជន៍ ជាអ្វីៗដែលមាន ប្រយោជន៍ ដែលគួរឱ្យចង់បាន។ អត្ថប្រយោជន៍ មានន័យថាជាអំណោយអ្វីមួយ កម្ចី តម្លៃឈ្នួល រង្វាន់ ឬកម្រៃជើងសារដែលមិនមានការអនុញ្ញាតដោយច្បាប់ជាធរមាន ជាទឹកប្រាក់ ឬជាវត្ថុមានតម្លៃ ឬជាទ្រព្យសម្បត្តិប្រភេទអ្វីមួយ[9]។

**២.៣.២ និយមន័យមធ្យោបាយដឹកជញ្ជូន**

មធ្យោបាយដឹកជញ្ជូន សំដៅដល់មធ្យោបាយដឹកជញ្ជូនដូចជា កប៉ាល់ សាឡង់ ទូក កាណូត អូប៉ររថយន្ត ក្បាលរថយន្តសណ្តោង រ៉ឺម៉កសណ្តោង ស៊ីមីរ៉ឺម៉កសណ្តោង ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល[10]។

[6] រៀបរៀងដោយនិស្សិតឈ្មោះ នូ មុល្លិកា, ច្រឹក ឆេងទីន, ប៉ូ ស៊ីវម៉ី, តាយ ស៊ីវអេង. (2023). ប្រធានបទ៖ *ដំណើរការនៃការប្រមូលពន្ធលើប្រាក់បៀវត្សរបស់អគ្គនាយកដ្ឋានដារ.* សារណាបញ្ចប់ថ្នាក់បរិញ្ញបត្រជំនាញ គណនេយ្យហិរញ្ញវត្ថុ ជំនាន់ទី២០. វិទ្យាស្ថានវ៉ាន់ដា. ភ្នំពេញ។

[7] សន្ទានុក្រមពន្ធដារ. (២០២២). *ពន្ធលើមធ្យោបាយដឹកជញ្ជូន.* ទំព័រ ២២។

[8] សង្គប្ប. វចនានុក្រមសង្គប្ប. (2023). *ផលប្រយោជន៍.* Retrieved from https://www.sangapac.com/dictionary/a/6858

[9] Video Learnig.com. ដកស្រង់ពីវចនានុក្រមសម្តេចព្រះសង្ឃរាជ ជួន ណាត. (2023, June). *អត្ថប្រយោជន៍.* Retrieved from https://videoslearning.com/1-5492/

[10] វិទ្យាស្ថានវ៉ាន់ដា. (២០២៤). *ច្បាប់ពន្ធដារកម្ពុជា.* បោះពុម្ពលើកទី១. ទំព័រទី១៦៨ទំព័រ. ភ្នំពេញ។

អ្នកជាប់ពន្ធ សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាកម្មសិទ្ធិករ ឬអ្នកកាន់កាប់មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ[11]។

[11] អគ្គនាយកដ្ឋានពន្ធដារ. *និយមន័យមធ្យោបាយដឹកជញ្ជូន*. Retrieved March 05 2025 from https://www.tax.gov.kh/u6rhf7ogbi6/gdtstream/c1440a39-3dec-4a3e-b3e1-7ba44ebf6002

# ជំពូកទី៣
# ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់ អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិសង្ខេបនៃអគ្គនាយកដ្ឋានពន្ធដារ




រដ្ឋខ្មែរ បានចាប់កំណើតតាំងពីសតវត្សទី១នៃគ្រឹស្តសករាជមកម្ល៉េះ ពោលគឺសម័យកាលហ្វូណន។ តាមប្រវត្តិសាស្ត្រ បន្តពីសម័យហ្វូណនមានសម័យកាលជាច្រើនទៀតជាអាទិ៍ សម័យចេនឡា សម័យអង្គរ សម័យលង្វែក សម័យឧត្តុង្គ និងសម័យចតុមុខ។ ការកំណត់សម័យកាលទាំងនេះធ្វើឡើងដោយផ្អែកលើការផ្លាស់ប្តូររាជធានីពីកន្លែងមួយទៅកន្លែងមួយទៀត ដែលមានរយៈពេលប្រមាណជា ១,៥០០ឆ្នាំ។ នៅក្នុងសម័យកាលទាំងនេះយើងសង្កេតឃើញថា ព្រះរាជាបានប្រមូលពន្ធពីប្រជារាស្ត្រដោយសារព្រះអង្គបានប្រទានដីធ្លីដល់ប្រជានុរាស្ត្រ ដើម្បីប្រកបអាជីវកម្ម និងកសិកម្មជាដើម។

កម្ពុជាមានភាពពិបាកក្នុងការវិលត្រឡប់ទៅរកការអនុវត្តច្បាប់ខ្មែរបុរាណវិញណាស់ពោលគឺ កម្ពុជាបានក្លាយជាប្រទេសនៃគ្រួសារប្រព័ន្ធច្បាប់រ៉ូម៉ាំង អាល្លឺម៉ង់រួចទៅហើយ។ ច្បាប់ពន្ធដារនៅកម្ពុជាគឺជាច្បាប់ពន្ធដារដែលមានឫសគល់ចេញមកពីច្បាប់បារាំង។ ប្រព័ន្ធពន្ធដារ ត្រូវលុបបំបាត់ចោលនៅក្នុងឆ្នាំ ១៨៦៣

ដល់ឆ្នាំ ១៩៧៥ បារាំងបានចូលមកធ្វើជាអាណាព្យាបាលខ្មែរ ហើយក្រោយមកបានប្រែក្លាយកម្ពុជា ទៅជាទឹកដីអាណានិគមរបស់ខ្លួននៅឆ្នាំ១៨៨៤ បារាំងបាននាំយកច្បាប់និងការគ្រប់គ្រងរដ្ឋបាលមកអនុវត្តនៅក្នុងប្រទេសកម្ពុជាជាពិសេសវិស័យសារពើពន្ធ។ ក្រោយពេលដែលទទួលបានឯករាជ្យពីអាណានិគមនិយមបារាំង នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ដល់ឆ្នាំ១៩៧៩ ដោយសារមានការកើតមានឡើងនៅសង្គ្រាម (របបខ្មែរក្រហម ឬរបបប៉ុលពត) និងបានធ្វើឱ្យប្រជាជនជួបនៅភាពលំបាក ការបាត់បង់ជីវិតជាច្រើននាក់ផងដែរ។ ប្រព័ន្ធពន្ធដារត្រូវបានបង្កើតឡើងវិញដំបូងនៅឆ្នាំ ១៩៨២ ដែលបានអនុវត្តឡើងនៅរាជធានីភ្នំពេញនិងខេត្តចំនួន១០ ផ្សេងទៀតដែលគេហៅថា របបម៉ៅការហើយបានគ្រប់គ្រងដោយ នាយកដ្ឋានពន្ធដារ។លើសពីនេះទៅទៀតនាយកដ្ឋានពន្ធដារក៏បានបង្កើតពន្ធមួយចំនួន ដើម្បីអនុវត្តន៍ និងមានការចែងច្បាប់និងមាត្រាយ៉ាងច្បាស់លាស់។

**សរុបរួមប្រវត្តិរបស់ពន្ធដារ៖**

- ១៩៥៣ : ត្រូវបានបង្កើតឡើងជានាយកដ្ឋានពន្ធដារ
- ១៩៧៥ ដល់ ១៩៧៩ : ពន្ធដារត្រូវលុបបំបាត់ចោលដោយរបបប៉ុលពត
- ១៩៨០ : នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងវិញ
- ២០០៨ : នាយកដ្ឋានពន្ធដារបានដំឡើងទៅជា អគ្គនាយកដ្ឋានពន្ធដារ ដោយសាលាជាតិពន្ធដារ។

### ៣.១.២ ទស្សនវិស័យ បេសកកម្ម គុណតម្លៃ របស់អគ្គនាយកដ្ឋានពន្ធដារ

**ក.ទស្សនវិស័យ**

អគ្គនាយកដ្ឋានពន្ធដារ ជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព។

**ខ.បេសកកម្ម**

អគ្គនាយកដ្ឋានពន្ធដារ ផ្តល់នូវសេវាដែលមានគុណភាព និងពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធទាំងអស់ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការអភិវឌ្ឍ និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

**គ.គុណតម្លៃ**

អគ្គនាយកដ្ឋានពន្ធដារ បំពេញបេសកកម្ម និងធ្វើប្រតិបត្តិការរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគុណតម្លៃដូចខាងក្រោម៖

- ការអនុវត្ត៖ អនុវត្តវិធាននៃច្បាប់ គាំទ្រប្រជាពលរដ្ឋដែលប្រព្រឹត្តត្រឹមត្រូវ តាមច្បាប់ និងតឹងរ៉ឹងចំពោះជនដែលមិនអនុលោមតាមច្បាប់
- វិជ្ជាជីវៈ៖ ប្តេជ្ញាចិត្តប្រើវិជ្ជាជីវៈ និងជំនាញ ដើម្បីផ្តល់នូវសេវាដែលមាន ភាពសាមញ្ញ និងងាយស្រួល
- ស័ក្តិសិទ្ធិភាព៖ ប្រើប្រាស់ធនធានឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព
- សុចរិតភាព៖ ផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព និងតម្លាភាព
- គារវភាព៖ ផ្តល់សេវាឱ្យប្រជាពលរដ្ឋប្រកបដោយភាពថ្លៃថ្នូរ និងការគោរព

- ភាពបត់បែន៖ ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន។

### ៣.១.៣ រចនាសម្ព័ន្ធគ្រប់គ្រង តួនាទី និងភារកិច្ច

#### ក. រចនាសម្ព័ន្ធគ្រប់គ្រង



ខ. តួនាទីគណៈគ្រប់គ្រង

- **ឯកឧត្តម គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ
- **ឯកឧត្តម អ៊ុំ សីហា** អគ្គនាយករង
- **ឯកឧត្តម ជាប ជាវុធ** អគ្គនាយករង
- **ឯកឧត្តម ម៉ិញ បានកុសល** អគ្គនាយករង
- **ឯកឧត្តម កែន សម្បត្តិ** អគ្គនាយករង
- **ឯកឧត្តម ហេង សុខណាង** អគ្គនាយករង
- **លោកជំទាវ ម៉ុន នារី** អគ្គនាយករង
- **ឯកឧត្តម វ៉ែន មុនី** អគ្គនាយករង
- **លោក លីម ដឺលុច** អគ្គនាយករង
- **ឯកឧត្តម លឹម ហ៊ុយជីវ** អគ្គនាយករង

**នាយកដ្ឋាននៃអគ្គនាយកដ្ឋានពន្ធដារ**

នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និង សហប្រតិបត្តិការពន្ធដារអន្តរជាតិ
នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម
នាយកដ្ឋានសវនកម្មសហគ្រាស
សាលាជាតិពន្ធដារ
ទីចាត់ការពន្ធដាររាជធានីភ្នំពេញ
អង្គភាពសវនកម្មពន្ធដារពិសេស

**សាខាពន្ធដារខណ្ឌ-ខេត្ត**

សាខាពន្ធដារខណ្ឌ ឫស្សីកែវ
សាខាពន្ធដារខណ្ឌ ដូនពេញ
សាខាពន្ធដារខណ្ឌ ៧មករា
សាខាពន្ធដារខណ្ឌ មានជ័យ
សាខាពន្ធដារខណ្ឌ ចំការមន
សាខាពន្ធដារខណ្ឌ ទួលគោក
សាខាពន្ធដារខណ្ឌ ដង្កោ

សាខាពន្ធដារខណ្ឌ សែនសុខ

សាខាពន្ធដារខណ្ឌ ពោធិ៍សែនជ័យ

សាខាពន្ធដារខេត្ត កណ្ដាល

សាខាពន្ធដារខេត្ត កំពង់ចាម

សាខាពន្ធដារខេត្ត បាត់ដំបង

សាខាពន្ធដារខេត្ត ព្រៃវែង

សាខាពន្ធដារខេត្ត សៀមរាប

សាខាពន្ធដារខេត្ត កំពង់ធំ

សាខាពន្ធដារខេត្ត តាកែវ

សាខាពន្ធដារខេត្ត ស្វាយរៀង

សាខាពន្ធដារខេត្ត ពោធិ៍សាត់

សាខាពន្ធដារខេត្ត កំពង់ឆ្នាំង

សាខាពន្ធដារខេត្ត កំពង់ស្ពឺ

សាខាពន្ធដារខេត្ត កំពត

សាខាពន្ធដារខេត្ត ព្រះសីហនុ

សាខាពន្ធដារខេត្ត កោះកុង

សាខាពន្ធដារខេត្ត ព្រះវិហារ

សាខាពន្ធដារខេត្ត ក្រចេះ

សាខាពន្ធដារខេត្ត រតនគិរី

សាខាពន្ធដារខេត្ត មណ្ឌលគិរី

សាខាពន្ធដារខេត្ត បន្ទាយមានជ័យ

សាខាពន្ធដារខេត្ត ស្ទឹងត្រែង

សាខាពន្ធដារខេត្ត កែប

សាខាពន្ធដារខេត្ត ប៉ៃលិន

សាខាពន្ធដារខេត្ត ឧត្ដរមានជ័យ

សាខាពន្ធដារខេត្ត ត្បូងឃ្មុំ

**គ. អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ច**

- រៀបចំគោលនយោបាយសារពើពន្ធស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបរិបទអន្តរជាតិការបង់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- រៀបចំសេចក្ដីព្រាងច្បាប់លិខិតបទដ្ឋាននានាស្ដីពីពន្ធដារ កំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការនានា សម្រាប់ការគ្រប់គ្រងប្រមូលពន្ធ
- ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- ចុះបញ្ជីអ្នកជាប់ពន្ធ

- ផ្តល់ការអប់រំដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធ ផ្តល់សេវានិងពត៌មានដល់អ្នកជាប់ពន្ធដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- កសាងកម្មវិធី សវនកម្មនិងធ្វើសវនកម្មលើអ្នកជាប់ពន្ធ
- កំណត់មូលដ្ឋានគិតពន្ធ ប្រាក់ពន្ធ ពន្ធបន្ថែមនិងការប្រាក់យឺតយ៉ាវចំពោះអ្នកជាប់ពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ
- អនុវត្តវិធានការតឹងទារនិងទោសទណ្ឌតាមច្បាប់ចំពោះអ្នកជាប់ពន្ធដែលប្រព្រឹត្តល្មើសនឹងច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- ធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ
- រៀបចំនិងអនុវត្តកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិនានាទាក់ទិននឹងពន្ធដារ
- រៀបចំផែនការជ្រើសរើស បណ្តុះបណ្តាល និងកសាងសមត្ថភាពធនធានមនុស្សទាក់ទងនឹងពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិនិងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

**ឃ.មធ្យោបាយដឹកជញ្ជូនក្នុងប្រទេសកម្ពុជា**

បច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជា មានមធ្យោបាយដឹកជញ្ជូនចំនួន៤ប្រភេទដូចខាងក្រោម៖

❖ **មធ្យោបាយដឹកជញ្ជូនតាមផ្លូវដែក**

ផ្លូវដែកកម្ពុជា បានចាប់ផ្តើមសាងសង់ដំបូងក្នុងទសវត្សឆ្នាំ១៩៣០ ដល់ឆ្នាំ១៩៤០ ។ ផ្លូវដែកកម្ពុជាមានចំនួន ២ខ្សែ គឺខ្សែភាគខាងជើង និងខ្សែភាគខាងត្បូង ដែលមានប្រវែងសរុប ៦៥០គីឡូម៉ែត្រ។ ផ្លូវដែកភាគខាងជើងមានប្រវែង ៣៨៦គីឡូម៉ែត្រ ពីភ្នំពេញទៅដល់ប៉ោយប៉ែត (ព្រំ ដែន កម្ពុជា-ថៃ) ត្រូវបានកសាងឡើងចាប់ ពីឆ្នាំ១៩២៩ ដល់ឆ្នាំ១៩៤២ ក្នុងសម័យអាណានិគមបារាំង និងផ្លូវដែកភាគខាងត្បូងត្រូវបានកសាងឡើងចន្លោះឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៩ ក្នុងសម័យសង្គមរាស្ត្រនិយម ក្រោមព្រះរាជកិច្ចដឹកនាំ របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ ក្រោមជំនួយរបស់ប្រទេសបារាំង អាល្លឺម៉ង់ខាងលិច និងចិន ដែលមានប្រវែងសរុប២៦៤គីឡូម៉ែត្រ។ ផ្លូវដែកទាំងពីរខ្សែនេះ ត្រូវបានទទួល រងការខ្ទេចខ្ទាំយ៉ាងធ្ងន់ធ្ងរ ហើយផ្នែកខ្លះត្រូវបានបំផ្លាញទាំងស្រុងដោយរបបកម្ពុជាប្រជាធិបតេយ្យ។

**គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវដែកសម្រាប់ពេលបច្ចុប្បន្ន និងអនាគត**

- ប៉ោយប៉ែត-សិរីសោភ័ណ ៤៨គម កំណល់បេតុងអាចទ្រទំងន់បាន ២០តោន/អក្សភ្លៅ (ដាក់ដំណើរការថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៨)
- សិរីសោភ័ណ-បាត់ដំបង ៦៥គម កំណល់ដែកអាចទ្រទំងន់បាន ១៥ តោន/អក្សភ្លៅ ( ដាក់ដំណើរការថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨)
- បាត់ដំបង-ពោធិសាត់ ១០៧គម កំណល់ដែក អាចទ្រទំងន់បាន ១៥តោន/អក្សភ្លៅ (ដាក់ដំណើរការថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៨)
- ពោធិសាត់-បាត់ដឹង ១៣៤គម និង បាត់ដឹង-ភ្នំពេញ ៣២គម កំណល់ដែក អាចទ្រទំងន់បាន១៥តោន/អក្សភ្លៅ (ដាក់ដំណើរការ ថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០១៨)។



❖ **មធ្យោបាយដឹកជញ្ជូនតាមផ្លូវទឹក**

- បច្ចុប្បន្នយើងមាននាវាចំនួន ០៤គ្រឿង សម្រាប់ដឹកជញ្ជូនអ្នកដំណើរ ព្រែកព្នៅ-ភ្នំពេញ-តាខ្មៅ ប្រកបដោយសុវត្ថិភាពខ្ពស់តាមស្តង់ដារអន្តរជាតិ។
- សូមជម្រាបជូនថា ការធ្វើដំណើរចាប់ពីព្រែកព្នៅ ទៅក្រុងតាខ្មៅ ត្រូវឆ្លងកាត់ស្ថានីយចំនួន ០៦គឺ ស្ថានីយចំនួន០៤ កំពុងដំណើរការ និងស្ថានីយចំនួន០២ទៀតដាក់ឱ្យដំណើរការនៅពេលខាងមុខ៖
  - ➢ ស្ថានីយព្រែកព្នៅ (កំពុងសាងសង់)
  - ➢ ស្ថានីយឫស្សីកែវ (កំពុងដំណើរការ)
  - ➢ ស្ថានីយផ្សារចាស់ (កំពុងដំណើរការ)
  - ➢ ស្ថានីយចតុមុខ (កំពុងដំណើរការ)
  - ➢ ស្ថានីយច្បារអំពៅ (កំពុងសាងសង់)
  - ➢ ស្ថានីយតាខ្មៅ (កំពុងសាងសង់)

❖ ការធ្វើដំណើរពីចំណតមួយទៅចំណតមួយប្រើរយៈពេលពី ៣នាទី ទៅ១០នាទី និងឈប់ដាក់អ្នកដំណើរឡើងចុះមិនលើសពី១០នាទីឡើយ។

❖ នាវាដឹកអ្នកដំណើរនេះមានល្បឿនជាមធ្យម៤០គីឡូម៉ែត្រក្នុងមួយម៉ោង និងប្រើរយៈពេលប្រហែល ៤៥នាទីប៉ុណ្ណោះពីព្រែកព្នៅទៅតាខ្មៅ និងពីតាខ្មៅទៅព្រែកព្នៅវិញ។

❖ សេវាដឹកអ្នកដំណើរតាមផ្លូវទឹកនេះមានដំណើរការជាប្រចាំ គឺចាប់ពីម៉ោង៥:៣០នាទីព្រឹក រហូតដល់ម៉ោង ៥:៣០នាទៅល្ងាច និងប្រតិបត្តិការ ០៧ថ្ងៃក្នុងមួយសប្តាហ៍ការធ្វើដំណើរតាមផ្លូវទឹកនេះមិនគិតថ្លៃសំបុត្ររហូតដល់ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៨។




❖ **មធ្យោបាយដឹកជញ្ជូនតាមផ្លូវគោក**

ការដឹកជញ្ជូនតាមផ្លូវគោក វាជាអ្វីគ្រប់យ៉ាងដែលកើនឡើងនៅលើផ្ទៃផែនដី។ ការដឹកជញ្ជូនប្រភេទនេះកើនឡើងពីតម្រូវការផ្ទាល់ខ្លួនរបស់មនុស្សក្នុងការធ្វើដំណើរផ្លូវឆ្ងាយដោយប្រើសមត្ថភាព និងល្បឿនលឿន។ ហើយបណ្តាញផ្លូវថ្នល់កម្រិតទី០១ មានផ្លូវក្រាលកៅស៊ូសរុបប្រវែងជាង ២,១១០គីឡូម៉ែត្រ ដែលភ្ជាប់ទំនាក់ទំនងប្រទេសកម្ពុជា ជាមួយនិងតំបន់តាមព្រំដែនរបស់ខ្លួន ជាមួយមហាអនុតំបន់ទន្លេមេគង្គ ជាមួយនិងបណ្តាញផ្លូវថ្នល់របស់អាស៊ាន។ ផ្លូវជាតិកម្រិតទី២មានប្រវែង ៣,១៤៦គីឡូម៉ែត្រ ហើយភាគច្រើនគឺជាផ្លូវដែលមិនក្រាលកៅស៊ូ ហើយផ្លូវខេត្តមិនក្រាលកៅស៊ូ មានប្រវែង ៦,៤៤១គីឡូម៉ែត្រ។ គោលដៅ គឺចង់បានផ្លូវក្រាលកៅស៊ូប្រវែង២,៥៨០គីឡូម៉ែត្រ នៅឆ្នាំ ២០១០ និង ៤,១០០គីឡូម៉ែត្រ នៅឆ្នាំ២០១៥។ បច្ចុប្បន្ននេះការងារម៉ោការស្ថាបនាផ្លូវថ្នល់ នឹងអាច បង្កើតបណ្តាញផ្លូវក្រាលកៅស៊ូ ដែលមានប្រវែងសរុប ៣,៤០០គីឡូម៉ែត្រ នៅក្នុងរយៈពេល ៣ឆ្នាំ ពោលគឺរហូតដល់ឆ្នាំ២០១៣ ដែលមានបង្ហាញគោលដៅខាងលើទំនងជាអាចសម្រេចបាន។



❖ មធ្យោបាយដឹកជញ្ជូនតាមផ្លូវអាកាស

ការដឹកជញ្ជូនតាមផ្លូវអាកាស ត្រូវបានគេស្គាល់ថាជាទំនិញតាមអាកាស សំដៅលើការដឹកជញ្ជូនទំនិញ និងទំនិញតាមអាកាសដោយប្រើយន្តហោះ។ វាជាវិធីសាស្ត្រលឿននិងមានប្រសិទ្ធភាពក្នុងការដឹកជញ្ជូនទំនិញក្នុងរយៈចម្ងាយឆ្ងាយ ជាពិសេសសម្រាប់ផលិតផលដែលមានតម្លៃខ្ពស់ និងពេលវេលា។ ការដឹកជញ្ជូនតាមផ្លូវអាកាសត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុងពាណិជ្ជកម្មអន្តរជាតិ និងការដឹកជញ្ជូន ការតភ្ជាប់អាជីវកម្ម និងអ្នកប្រើប្រាស់នៅទូទាំងពិភពលោក។

នេះគឺជាលក្ខណៈសំខាន់ៗ និងអត្ថប្រយោជន៍នៃការដឹកជញ្ជូនតាមផ្លូវអាកាស៖

- ល្បឿន: ការដឹកជញ្ជូនតាមផ្លូវអាកាសគឺជាមធ្យោបាយដឹកជញ្ជូនលឿនបំផុតមួយដែលអាចរកបាន។ ទំនិញអាចត្រូវបានដឹកជញ្ជូនរវាងប្រទេស ឬទ្វីបក្នុងរយៈពេលប៉ុន្មានម៉ោង ឬច្រើនថ្ងៃ ដែលធ្វើឱ្យវាល្អសម្រាប់ការដឹកជញ្ជូនពេលវេលាដ៏សំខាន់។
- ការឈានដល់ពិភពលោក៖ ក្រុមហ៊ុនអាកាសចរណ៍ដំណើរការបណ្តាញផ្លូវហោះហើរដ៏ធំទូលាយ ដែលគ្របដណ្តប់ទីក្រុង និងអាកាសយានដ្ឋានធំៗទូទាំងពិភពលោក។ ការឈានទៅដល់ដ៏ទូលំទូលាយនេះអនុញ្ញាតឱ្យទំនិញត្រូវបានដឹកជញ្ជូនទៅកាន់ស្ទើរតែគ្រប់គោលដៅដែលមានព្រលានយន្តហោះ។
- ភាពជឿជាក់៖ ការដឹកជញ្ជូនតាមផ្លូវអាកាសត្រូវបានគេស្គាល់ថាសម្រាប់កម្រិតខ្ពស់នៃភាពជឿជាក់ និងដំណើរការដឹកជញ្ជូនទាន់ពេលវេលា។ ក្រុមហ៊ុនអាកាសចរណ៍ជាធម្មតាប្រកាន់ខ្ជាប់នូវកាលវិភាគដ៏តឹងរឹង ដោយកាត់បន្ថយលទ្ធភាពនៃការពន្យារពេល។

- សន្តិសុខនិងសុវត្ថិភាព៖ ទំនិញតាមអាកាសគឺស្ថិតនៅក្រោមវិធានការសន្តិសុខយ៉ាងតឹងរ៉ឹងនៅព្រលានយន្តហោះ ដែលធ្វើឱ្យវាក្លាយជាជម្រើសសុវត្ថិភាពសម្រាប់ការដឹកជញ្ជូនទំនិញមានតម្លៃ ។
- កាត់បន្ថយថ្លៃដើមស្តុកទុក៖ ល្បឿននៃការដឹកជញ្ជូនតាមផ្លូវអាកាសអាចជួយឱ្យអាជីវកម្មកាត់បន្ថយការចំណាយលើការរក្សាទុកសារពើភណ្ឌ ព្រោះថាទំនិញអាចផ្ទុកឡើងវិញបានយ៉ាងឆាប់រហ័សនៅពេលចាំបាច់។
- ការតាមដានពេលវេលាពិត៖ សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសជាច្រើនផ្តល់ជូននូវការតាមដាន និងត្រួតពិនិត្យការដឹកជញ្ជូនតាមពេលវេលាជាក់ស្តែង ដែលអនុញ្ញាតឱ្យអ្នកដឹកជញ្ជូន និងអ្នកទទួលដឹងពីទីតាំង និងស្ថានភាពពិតប្រាកដនៃទំនិញរបស់ពួកគេក្នុងអំឡុងពេលដឹកជញ្ជូន។
- ជម្រើសគ្រប់គ្រងសីតុណ្ហភាព៖ ការដឹកជញ្ជូនតាមផ្លូវអាកាសផ្តល់នូវជម្រើសដែលគ្រប់គ្រងដោយសីតុណ្ហភាពសម្រាប់ការដឹកជញ្ជូនទំនិញដែលអាចខូចបាន ឬងាយរងគ្រោះដែលត្រូវការលក្ខខណ្ឌបរិស្ថានជាក់លាក់។
- ការបោសសំអាតគយ៖ ការដឹកជញ្ជូនតាមផ្លូវអាកាសជារឿយៗពាក់ព័ន្ធនឹងដំណើរការបោសសំអាតគយលឿនជាងបើប្រៀបធៀបទៅនឹងមធ្យោបាយដឹកជញ្ជូនផ្សេងទៀត ដោយកាត់បន្ថយពេលវេលាដែលទំនិញចំណាយនៅព្រំដែន។




ខណៈពេលដែលការដឹកជញ្ជូនតាមផ្លូវអាកាសផ្តល់នូវអត្ថប្រយោជន៍ជាច្រើន វាអាចមានតម្លៃថ្លៃជាងមធ្យោបាយដឹកជញ្ជូនផ្សេងទៀត ដូចជាការដឹកជញ្ជូនតាមសមុទ្រ។ តម្លៃនៃការដឹកជញ្ជូនតាមផ្លូវអាកាសជាធម្មតាត្រូវបានកំណត់ដោយទម្ងន់ បរិមាណ និងទិសដៅនៃការដឹកជញ្ជូន។

ការដឹកជញ្ជូនតាមផ្លូវអាកាសត្រូវបានប្រើប្រាស់ជាទូទៅសម្រាប់ការដឹកជញ្ជូនទំនិញដែលមានតម្លៃខ្ពស់ ទំនិញដែលអាចខូចបាន ឱសថ គ្រឿងអេឡិចត្រូនិច គ្រឿងបន្លាស់រថយន្ត ផលិតផលម៉ូដ និងទំនិញដែលងាយរងគ្រោះដល់ពេលវេលា ឬតម្លៃពិសេសផ្សេងទៀត។ អាជីវកម្ម និងបុគ្គលតែងតែជ្រើសរើសការដឹកជញ្ជូនតាមផ្លូវអាកាស នៅពេលដែលល្បឿន ភាពជឿជាក់ និងការតភ្ជាប់សកលមានសារៈសំខាន់សម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ ឬតម្រូវការដឹកជញ្ជូនរបស់ពួកគេ។

## ៣.២ នីតិវិធីនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន

### ៣.២.១ នីតិវិធី

ដើម្បីឱ្យការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនប្រកបដោយប្រសិទ្ធភាពខ្ពស់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញសេចក្តីប្រកាសស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន លេខ៧៣៨ សហវ.ប្រក.អពជប្រការ១ប្រកាសនេះមានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន។ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិ។

**១. កម្មវត្ថុនៃពន្ធ**

ពន្ធលើមធ្យោបាយដឹកជញ្ជូន ជាពន្ធប្រចាំឆ្នាំ ដែលអនុវត្តន៍លើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយរួមមានៈ

- ❖ រថយន្តដឹកទំនិញ និងរ៉ឺម៉កសណ្តោង
- ❖ រថយន្តដឹកអ្នកដំណើរ
- ❖ រថយន្តទេសចរណ៍
- ❖ ជលយាន ឬជលយានយន្ត ផ្លូវទន្លេនិងសមុទ្រ។
- ❖ រថយន្តដឹកទំនិញ (Pick Up) និងដឹកអ្នកដំណើរត្រូវចាត់ជារថយន្តទេសចរណ៍ចំពោះ រថយន្តដែលមាន ពីឆ្នាំផលិតដល់ ៥ (ប្រាំ)ឆ្នាំ។



២.មូលដ្ឋានគិតពន្ធ

មូលដ្ឋានគិតពន្ធ អត្រាពន្ធ និងការគណនាពន្ធ គិតទៅតាមប្រភេទយានជំនិះ។

- **រថយន្តដឹកទំនិញ៖** គិតលើទម្ងន់សរុប

ទម្ងន់សរុប = ទម្ងន់រថយន្ត + ទម្ងន់ផ្ទុក ( ទំនិញ+មនុស្ស )

ចាត់ជារថយន្តដឹកទំនិញចំពោះក្បាលរថយន្តសណ្តោង និងសីមុីរ៉ឺម៉កសណ្តោង ត្រូវបង់ពន្ធរួមគ្នា ករណីមានរ៉ឺម៉កសណ្តោងបន្ថែមទៀត ត្រូវបង់ពន្ធដោយឡែក។

- **រថយន្តដឹកអ្នកដំណើរ៖** គិតលើចំនួនកៅអី។
- **ជលយាន ឬជលយានយន្ត ដែកទំនិញ៖** គិតលើទម្ងន់ទំនិញ។
- **ជលយាន ឬជលយានយន្ត សណ្តោង និងនេសាទ៖** គិតលើកម្លាំងម៉ាស៊ីន។
- **រថយន្តទេសចរណ៍៖** ទំហំស៊ីឡាំង និងឆ្នាំផលិត។

## ៣.ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវបានកំណត់តាមអត្រាដូចខាងក្រោម៖

❖ មធ្យោបាយដឹកជញ្ជូនទូទៅ៖

| ល.រ | ប្រភេទមធ្យោបាយដឹកជញ្ជូន | កម្រិតប្រាក់ពន្ធ សម្រាប់១ឆ្នាំ/គ្រឿង (គិតជារៀល) |
|---|---|---|
| ក | រថយន្តដឹកទំនិញមានទម្ងន់សរុប(ទម្ងន់រថយន្តនិងទម្ងន់ផ្ទុក (ទំនិញនិងមនុស្ស) | |
| | -ដល់ ៣តោន | ២០០,០០០ |
| | -លើសពី ៣តោន ដល់ ១០តោន | ៥០០,០០០ |
| | -លើសពី១០តោន ដល់ ២០តោន | ១,០០០,០០០ |
| | -លើសពី២០តោនឡើងទៅ | ២,០០០,០០០ |
| ខ | ក្បាលរថយន្តសណ្តោងរួម និងស៊ីមីរ៉ឺម៉កសណ្តោង៖ | ២,០០០,០០០ |
| គ | រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (ទម្ងន់រ៉ឺម៉កនិងទម្ងន់ផ្ទុក)៖ | |
| | -លើសពី ៣តោន ដល់ ១០តោន | ៥០០,០០០ |
| | -លើសពី១០តោន ដល់ ២០តោន | ១,០០០,០០០ |
| | -លើសពី២០តោនឡើងទៅ | ២,០០០,០០០ |
| ឃ | ជលយានឬជលយានយន្តផ្លូវទន្លេ៖ | |
| | +ដល់ ៣តោន | ៥០,០០០ |
| | +លើសពី ៣តោន ដល់ ១០តោន | ១០០,០០០ |
| | +លើសពី១០តោន ដល់ ២០តោន | ២០០,០០០ |
| | +លើសពី២០តោនឡើងទៅ | ៣០០,០០០ |
| | -ជលយានឬជលយានយន្តដឹកអ្នកដំណើរ៖ | |
| | +កប៉ាល់មានបណ្តោយដល់ ២០ម៉ែត្រ | ១០០,០០០ |
| | +កប៉ាល់មានបណ្តោយលើសពី ២០ម៉ែត្រ ដល់ ៣០ម៉ែត្រ | ២០០,០០០ |
| | +កប៉ាល់មានបណ្តោយលើសពី ៣០ម៉ែត្រឡើងទៅ | ៣០០,០០០ |
| | -ជលយានឬជលយានយន្តសណ្តោង៖ | |
| | +កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៦០,០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | ១៨០,០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ២៥០សេះឡើងទៅ | ៣០០,០០០ |
| ង | ជលយានឬជលយានយន្តផ្លូវសមុទ្រ៖ | |
| | -ជលយានឬជលយានយន្តដឹកអ្នកដំណើរ៖ | |
| | +ទូកមានបណ្តោយដល់ ២០ម៉ែត្រ | ១០០,០០០ |
| | +ទូកមានបណ្តោយលើសពី ២០ម៉ែត្រឡើងទៅ | ១៥០,០០០ |
| | -ជលយានឬជលយានយន្តដឹកទំនិញ៖ | |
| | +ទូកផ្ទុកទំនិញដល់ ១០០តោន | ២០០,០០០ |
| | +កប៉ាល់ផ្ទុកទំនិញលើសពី ១០០តោន ដល់ ១,០០០តោន | ៣០០,០០០ |
| | +កប៉ាល់ផ្ទុកទំនិញលើសពី ១,០០០តោន ដល់ ២,០០០តោន | ៧៥០,០០០ |
| | +កប៉ាល់ផ្ទុកទំនិញលើសពី ២,០០០តោន ឡើងទៅ | ១,២០០,០០០ |
| | -ជលយានឬជលយានយន្តនេសាទ៖ | |

| | | | |
|---|---|---|---|
| | | +ទូកមានកម្លាំងលើសពី ១៥០សេះ ឡើងទៅ | ១០០,000 |
| | | +កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២៥០សេះ | ៤០០,000 |
| | | +កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៦០០,000 |
| | | +កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | ១,២០០,000 |
| | -ជលយានឬជលយានយន្តសណ្តោង៖ | | |
| | | +កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | ២០០,000 |
| | | +កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៤០០,000 |
| | | +កប៉ាល់មានកម្លាំងលើសពី ៥០០សេះឡើងទៅ | ៦០០,000 |
| ច | អូប័រផ្លូវទន្លេឬសមុទ្រ៖ | | |
| | -មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | | ៤០០,000 |
| | -មានកម្លាំងលើសពី ២០០សេះ ឡើងទៅ | | ៥០០,000 |

❖ មធ្យោបាយដឹកជញ្ជូនកែច្នៃ៖

| ល.រ | ប្រភេទមធ្យោបាយដឹកជញ្ជូន | កម្រិតប្រាក់ពន្ធ សម្រាប់១ឆ្នាំ/គ្រឿង (គិតជារៀល) |
|---|---|---|
| ក | រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៤ | ២០០,000 |
| ខ | រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៨ | ៥០០,000 |
| គ | រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ | ១,000,000 |
| ឃ | រថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ | ២,000,000 |

❖ រថយន្តទេសចរណ៍៖

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម៣ | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | ដល់៥ឆ្នាំ (គិតជារៀល) | លើសពី៥ឆ្នាំដល់១០ឆ្នាំ (គិតជារៀល) | លើសពី១០ឆ្នាំ (គិតជារៀល) |
| ក | ដល់ ១,៥០០ ស.ម៣ | ១៥០,000 | ១០០,000 | ៨០,000 |
| ខ | លើសពី ១,៥០០ ស.ម៣ ដល់ ២,000 ស.ម៣ | ២០០,000 | ១៥០,000 | ១០០,000 |
| គ | លើសពី ២,000 ស.ម៣ ដល់ ២,៩០០ ស.ម៣ | ៦០០,000 | ៤០០,000 | ២៥០,000 |
| ឃ | លើសពី ២,៩០០ ស.ម៣ ដល់ ៤,000 ស.ម៣ | ១,៦០០,000 | ១,000,000 | ៦០០,000 |
| ង | លើសពី ៤,000 ស.ម៣ ឡើងទៅ | ២,000,000 | ១,២០០,000 | ៨០០,000 |

❖ រថយន្តដឹកទំនិញធុនតូចមានទ្វារ៤ (ភិកអាប់)៖

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម៣ | គិតពីឆ្នាំផលិត | |
|---|---|---|---|
| | | ដល់៥ឆ្នាំ (គិតជារៀល) | លើសពី៥ឆ្នាំ (គិតជារៀល) |
| ក | ដល់ ១,៥០០ ស.ម៣ | ១៥០,000 | ១០០,000 |
| ខ | លើសពី ១,៥០០ ស.ម៣ ដល់ ២,000 ស.ម៣ | ២០០,000 | ១៥០,000 |
| គ | លើសពី ២,000 ស.ម៣ ដល់ ២,៩០០ ស.ម៣ | ៦០០,000 | ២០០,000 |

| | | | |
|---|---|---|---|
| ឃ | លើសពី ២,៩០០ ស.ម៣ ដល់ ៤,០០០ ស.ម៣ | ១,៦០០,០០០ | ២០០,០០០ |
| ង | លើសពី ៤,០០០ ស.ម៣ ឡើងទៅ | ២,០០០,០០០ | ២០០,០០០ |

❖ រថយន្តដឹកអ្នកដំណើរ៖

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម៣ | គិតពីឆ្នាំផលិតដល់៥ឆ្នាំ (គិតជារៀល) |
|---|---|---|
| ក | ដល់ ១,៥០០ ស.ម៣ | ១៥០,០០០ |
| ខ | លើសពី ១,៥០០ ស.ម៣ ដល់ ២,០០០ ស.ម៣ | ២០០,០០០ |
| គ | លើសពី ២,០០០ ស.ម៣ ដល់ ២,៩០០ ស.ម៣ | ៦០០,០០០ |
| ឃ | លើសពី ២,៩០០ ស.ម៣ ដល់ ៤,០០០ ស.ម៣ | ១,៦០០,០០០ |
| ង | លើសពី ៤,០០០ ស.ម៣ ឡើងទៅ | ២,០០០,០០០ |
| | **ចំនួនកៅអី** | **គិតពីឆ្នាំផលិតដល់៥ឆ្នាំ** (គិតជារៀល) |
| ច | រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | ១៥០,០០០ |
| ឆ | រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអី១៦កៅអី ដល់ ២៥កៅអី | ២០០,០០០ |
| ជ | រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអី លើស ២៥កៅអី ឡើងទៅ | ២៥០,០០០ |

❖ រថយន្តប្រើប្រាស់ថាមពលអគ្គិសនី(អ៊ីវី)ប្រភេទទេសចរណ៍ រថយន្តដឹកទំនិញធុនតូចមានទ្វា៤ (ភីកអាប់) និងរថយន្តដឹកអ្នកដំណើរ៖

| ល.រ | គិតជាកម្លាំងសេះ | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | **ដល់៥ឆ្នាំ** (គិតជារៀល) | **លើសពី៥ឆ្នាំដល់១០ឆ្នាំ** (គិតជារៀល) | **លើសពី១០ឆ្នាំ** (គិតជារៀល) |
| ក | ដល់ ១៥០សេះ | ១០០,០០០ | ៨០,០០០ | ៦០,០០០ |
| ខ | លើសពី ១៥០សេះ ដល់ ២០០សេះ | ១៥០,០០០ | ១០០,០០០ | ៨០,០០០ |
| គ | លើសពី ២០០សេះ ដល់ ២៥០សេះ | ៥០០,០០០ | ៣០០,០០០ | ១៥០,០០០ |
| ឃ | លើសពី ២៥០សេះ ដល់ ៣០០សេះ | ១,២០០,០០០ | ៨០០,០០០ | ៤០០,០០០ |
| ង | លើសពី ៣០០សេះ ឡើងទៅ | ១,៦០០,០០០ | ១,០០០,០០០ | ៦០០,០០០ |

## ៤.ការលើកលែងពន្ធ

ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវបានលើកលែងដូចខាងក្រោម៖

១. រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គិភ័យជាកម្មសិទ្ធរបស់រដ្ឋ។

២. យានយន្តដែលជាកម្មសិទ្ធរបស់អង្គភាពកងយោធាខេមរៈភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបម្រើការងារសម្រាប់គោលដៅនៃការការពារជាតិសន្តិសុខនិងសណ្តាប់ធ្នាប់សង្គមតែប៉ុណ្ណោះ ។

៣. យានយន្តដែលជាកម្មសិទ្ធរបស់ស្ថានទូត ស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេករបស់រដ្ឋាភិបាលនានា។

៤. ទោលចក្រយានយន្តនិងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រនិងគ្រឿងយន្តប្រហាក់ប្រហែល និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់១៥០(មួយរយហាសិប)សេះ ឬតិចជាង។

៥. រថយន្តដែលបំប្លែងមកពីគោយន្ត និងរថយន្តកែច្នៃកង់បីដែលបំពាក់ម៉ាស៊ីន។

### ៥.ការអនុវត្តពន្ធលើមធ្យោបាយដឹកជញ្ជូន

- ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវអនុវត្តចំពោះម្ចាស់កម្មសិទ្ធនៃមធ្យោបាយដឹកជញ្ជូន។
- ម្ចាស់កម្មសិទ្ធឬអ្នកតំណាង ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន ក្នុងកំឡុងពេលចាប់ពីថ្ងៃទី០១ ខែមិថុនា រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំ។
- ម្ចាស់កម្មសិទ្ធឬអ្នកតំណាង ត្រូវបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូននៅអគ្គនាយកដ្ឋានពន្ធដារ ឬនៅសាខាពន្ធដារខេត្ត ខណ្ឌ ឬធនាគារជាដៃគូរ ឬតាមរយៈកម្មវិធីទូរស័ព្ទដៃ។

### ៦.ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន

ដើម្បីធ្វើការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវអនុវត្តដូចខាងក្រោម៖

១- ម្ចាស់កម្មសិទ្ធិឬអ្នកតំណាង ត្រូវមកចុះបញ្ជីនិងដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធលើកដំបូង ដោយត្រូវបំពេញព័ត៌មានទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ និងត្រូវមានឯកសារ ដូចខាងក្រោម៖

ក- រថយន្តទេសចរណ៍៖

- ប្លាប់ដើមនៃបណ្ណសម្គាល់យានជំនិះ
- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតឆ្លងដែនរបស់ម្ចាស់កម្មសិទ្ធិ
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារចំពោះនីតិបុគ្គល។

ខ- រថយន្តដឹកទំនិញ ឬរថយន្តដឹកអ្នកដំណើរ ឬជលយានយន្ត៖

- ប្លាប់ដើមនៃបណ្ណសម្គាល់យានជំនិះ
- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតឆ្លងដែនរបស់ម្ចាស់កម្មសិទ្ធិ
- ប្លាប់ដើមនៃវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះដែលចេញដោយក្រសួងសាធារណៈការ និងដឹកជញ្ជូន
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារចំពោះនីតិបុគ្គល។

គ- យានយន្តកែច្នៃក្នុងស្រុក៖

- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតឆ្លងដែនរបស់ម្ចាស់កម្មសិទ្ធិ
- ប្លាប់ដើមនៃលិខិតបញ្ជាក់ការប្រើប្រាស់យានជំនិះចេញដោយឃុំ សង្កាត់
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារចំពោះនីតិបុគ្គល។

២- ម្ចាស់កម្មសិទ្ធិឬអ្នកតំណាងដែលបានចុះបញ្ជីនិងប្រកាស និងបង់ប្រាក់ពន្ធរួចម្តងមកហើយ ត្រូវមានឯកសារ ដូចខាងក្រោម៖

ក- បណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន

ខ- បណ្ណសម្គាល់យានជំនិះ

គ- បង្កាន់ដៃទទួលប្រាក់ពន្ធមធ្យោបាយដឹកជញ្ជូន

ឃ-លតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូនឆ្នាំចាស់។

៣-ចំពោះមធ្យោបាយដឹកជញ្ជូនដែលបានចុះបញ្ជី និងបានដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធរួច ហើយត្រូវបានប្តូរបណ្ណសម្គាល់យានជំនិះដោយសារមានការផ្លាស់ប្តូរព័ត៌មាន ម្ចាស់មធ្យោបាយដឹកជញ្ជូនត្រូវស្នើសុំធ្វើបច្ចុប្បន្នភាព ព័ត៌មានមធ្យោបាយដឹកជញ្ជូននោះ នៅអគ្គនាយកដ្ឋានពន្ធដារ ឬ នៅសាខាពន្ធដារខេត្ត ខណ្ឌដើម្បីប្រកាសបង់ពន្ធបន្ត ព្រមទាំងអាចប្តូរបណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូនផងដែរ។

៤- ក្រោយពេលបង់ពន្ធរួច ម្ចាស់មធ្យោបាយដឹកជញ្ជូនត្រូវទទួលបានបង្កាន់ដៃទទួលប្រាក់ពន្ធមធ្យោបាយដឹកជញ្ជូន និងលតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូន។ លតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូនត្រូវបិទភ្ជាប់ជាមួយនឹងមធ្យោបាយដឹកជញ្ជូននោះ ហើយបង្កាន់ដៃទទួលប្រាក់ពន្ធ អាចរក្សាទុកសម្រាប់ប្រើប្រាស់តាមការចាំបាច់។

៥- ម្ចាស់មធ្យោបាយដឹកជញ្ជូន អាចស្នើសុំបណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងបង់ថ្លៃសេវាចំនួន ៥,០០០ រៀល នៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត ខណ្ឌ ឬនៅធនាគារដៃគូ។ បណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូនមានទម្រង់ជាបណ្ណរឹង និងបណ្ណទម្រង់ឌីជីថល (E-CARD)។ បន្ទាប់ពីការបង់ប្រាក់ពន្ធនិងថ្លៃសេវា ម្ចាស់មធ្យោបាយដឹកជញ្ជូននឹងទទួលបានភ្លាមៗ នូវបណ្ណរឹង ពីអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត ខណ្ឌ ឬបណ្ណ ទម្រង់ឌីជីថល (E-CARD) តាមអនឡាញ។

៦- ករណីបាត់លតាបត្រ ម្ចាស់មធ្យោបាយដឹកជញ្ជូនអាចដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ការបង់ពន្ធលើមធ្យោបាយ ដឹកជញ្ជូន នៅអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត ខណ្ឌ ដើម្បីប្រើប្រាស់តាមការចាំបាច់។

### ៣.២.២ ការគណនាប្រាក់ពន្ធត្រូវបង់

អ្នកជាប់ពន្ធអាចស្វែងរកតាមប្រកាសលេខ ៥៣១ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ អាចប្រើប្រាស់កម្មវិធីទូរស័ព្ទ GDT Means of Transportation Tax Calculation ( ទាំងប្រព័ន្ធប្រតិបត្តិការ Android និង iOS) ដើម្បីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន។

**ឧទាហរណ៍៖ រថយន្តទេសចរណ៍**

ក. រថយន្តប្រភេទទេសចរណ៍ ផ្លាកលេខ ភ្នំពេញ 2T-1111 ម៉ាក LEXUS RX 350 មានទំហំស៊ីឡាំង 3500 CC ឆ្នាំផលិត ២០០៧

ខ. រថយន្តប្រភេទទេសចរណ៍ ផ្លាកលេខ ភ្នំពេញ 2AA-2222 ម៉ាក LEXUS RX 350 មានទំហំស៊ីឡាំង 3500 CC ឆ្នាំផលិត ២០១៥

តើរថយន្តនីមួយៗខាងលើត្រូវបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤ ចំនួនប៉ុន្មានរៀល?

**ចម្លើយ៖ ផ្អែកតាមតារាងឧបសម្ព័ន្ធ II នៃប្រកាសលេខ ៥៣១ សហវ.ប្រក បានកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវបង់សម្រាប់ឆ្នាំ២០២៤ ដូចខាងក្រោម៖**

ក. រថយន្តផ្លាកលេខ ភ្នំពេញ 2T-1111 ឆ្នាំផលិត២០០៧ ជារថយន្តដែលគិតពីឆ្នាំផលិតលើសពី ១០ឆ្នាំ ប្រាក់ពន្ធត្រូវបង់ចំនួន ៦០០,០០០ រៀល

ខ. រថយន្តផ្លាកលេខ ភ្នំពេញ 2AA-2222 ឆ្នាំផលិត ២០១៥ ជារថយន្តដែលគិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ប្រាក់ពន្ធត្រូវបង់ចំនួន ១,០០០,០០០ រៀល។

**ឧទាហរណ៍៖ រថយន្តដឹកទំនិញ**

ក. រថយន្តដឹកទំនិញមានផ្លាកលេខ ភ្នំពេញ 3A-4444 ម៉ាក HYUNDAI មានទម្ងន់ផ្ទុកសរុប (ទម្ងន់សរុប = ទម្ងន់រថយន្ត + ទម្ងន់ផ្ទុក និងមនុស្ស) ១៥ តោន

ខ. រថយន្តដឹកទំនិញមានផ្លាកលេខ ភ្នំពេញ 3B-5555 ម៉ាក HINO មានទម្ងន់ផ្ទុកសរុប (ទម្ងន់សរុប = ទម្ងន់រថយន្ត + ទម្ងន់ផ្ទុក និងមនុស្ស) ២៥ តោន ។

❖ តើរថយន្តនីមួយៗខាងលើត្រូវបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤ ចំនួនប៉ុន្មានរៀល?

✓ ចម្លើយ៖ ផ្អែកតាមតារាងឧបសម្ព័ន្ធ I នៃប្រកាសលេខ ៥៣១ សហវ.ប្រក បានកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវបង់សម្រាប់ឆ្នាំ២០២៤ ដូចខាងក្រោម៖

ក. រថយន្តផ្លាកលេខ ភ្នំពេញ 3A-4444 ម៉ាក HYUNDAI មានទម្ងន់ផ្ទុកសរុប ១៥ តោន ប្រាក់ពន្ធត្រូវបង់ចំនួន ១,០០០,០០០ រៀល

ខ. រថយន្តផ្លាកលេខ ភ្នំពេញ 3B-5555 ម៉ាក HINO មានទម្ងន់ផ្ទុកសរុប ២៥ តោន ប្រាក់ពន្ធត្រូវបង់ចំនួន ២,០០០,០០០ រៀល។

**<u>ការបង្ហាញចំណូលនៃការប្រមូលពន្ធចន្លោះឆ្នាំ ២០២២- ២០២៣</u>**

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ការប្រមូលចំណូលពន្ធដោយអគ្គនាយកដ្ឋានពន្ធដារឃើញថាមានភាពល្អប្រសើរ និងមានការកើនឡើងគួរឱ្យកត់សម្គាល់ដោយការប្រមូលចំណូលពន្ធបានលើសផែនការដែលបានគ្រោងទុក។

សម្រាប់ឆ្នាំ២០២១ ចំណូលពន្ធដែលបានមកពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនដែលអនុវត្តតាមច្បាប់ហិរញ្ញវត្ថុមានចំនួន ២២១,២៣៩លានរៀល បើធៀបនឹងឆ្នាំ២០២២ ដែលមានចំនួន ៣២៤,៥២៦លានរៀលគឺមានការកើនឡើងចំនួន ១០៣,២៨៧លានរៀល ត្រូវជា ៤៦.៧%។

# ការគ្រប់គ្រងឆ្នាំ២០២២

## តារាង ក២

ឯកតា:លានរៀល

## ចំណូលថវិការដ្ឋបាលរាជធានីខេត្ត

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២១ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០២២ | ប្រៀបធៀប ទឹកប្រាក់ | ប្រៀបធៀប ភាគរយ |
|---|---|---|---|---|---|---|---|
| **សរុបចំណូលថវិការាជធានី ខេត្ត** | | | | 2,203,579.0 | 2,859,652.0 | 656,073,0 | 29.8% |
| **សរុបចំណូលឆ្លងកាត់តេនាគារជាតិ** | | | | 2,203,579.0 | 2,859,652.0 | 656,073,0 | 29.8% |
| **ក្នុងនោះចំណូលក្នុងប្រទេស** | | | | 2,203,579.0 | 2,859,652.0 | 656,073,0 | 29.8% |
| **ក សរុបចំណូលក្នុងប្រទេស( ក្រ+ក្រ២ )** | | | | 2,203,579.0 | 2,859,652.0 | 656,073,0 | 29.8% |
| **ក្រុមទី១ ចំណូលពិត ( ប្រភេទទី១+ប្រភេទទី២ )** | | | | 2,203,579.0 | 2,859,652.0 | 656,073,0 | 29.8% |
| **ប្រភេទទី១ ចំណូលសារពើពន្ធ** | | | | 1,050,323.0 | 1,584,127.0 | 533,804,0 | 50,8% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 1,050,323.0 | 1,584,127.0 | 533,804,0 | 50.8% |
| | 7001 | | ពន្ធផ្ទាល់( ពន្ធលើផលទុនប្រាក់ចំណូល ) | 154,784.5 | 281,757.2 | 126,972,7 | 82.0% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល ) | 154,784.5 | 281,757.2 | 126,972,7 | 82.0% |
| | 7003 | | អាករពិសេស | 116,799.1 | 161,859.2 | 45,060,1 | 38.6% |
| | | 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | 116,799.1 | 161,859.2 | 45,060,1 | 38.6% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 4,998.0 | 2,872.9 | -2,125,1 | -42.5% |
| | | 70045 | អាករលើការស្នាក់នៅ | 4,998.0 | 2,872.9 | -2,125,1 | -42.5% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តសកម្មភាព | 256,238.5 | 399,321,0 | 143,082,5 | 55.8% |
| | | 70053 | ពន្ធប៉ាតង់ | 34,999.5 | 74,794,0 | 39,795,5 | 113.7% |
| | | 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ | 221,239.0 | 324,526.0 | 103,287.0 | 46.7% |
| | 7006 | | ពន្ធប្រថាប់ត្រា | 406,726.9 | 574,512,8 | 167,539,0 | 41.2% |
| | | 70061 | ពន្ធប្រថាប់ត្រាលើតម្លៃអចលនទ្រព្យចំពោះការផ្ទេរសិទ្ធិឬសិទ្ធិកាន់កាប់ | 398,973.0 | 560,512,0 | 16,1,539,0 | 40.5% |
| | | 70062 | ពន្ធប្រថាប់ត្រាលើតម្លៃមធ្យោបាយដឹកជញ្ជូលឬយានយន្តចំពោះការផ្ទេរសិទ្ធ | 4,485,2 | 5,770,3 | 1,285,1 | 28.7% |
| | | 70063 | ពន្ធប្រថាប់ត្រាលើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន | 1,079,0 | 3,558,2 | 2,479,2 | 229.8% |
| | | 70064 | ពន្ធប្រថាប់ត្រាលើតម្លៃភាគហ៊ុនចំពោះការផ្គត់ផ្គង់ទំនិញឬសេវា | 1,214.3 | 3558,2 | -2,306,2 | 189.9% |
| | | 70065 | ពន្ធប្រថាប់ត្រាលើលិខិតមានលក្ខណៈគតិយុត្ត | 975,4 | 930,8 | -44,6 | 4.6% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | 7007 | | ពន្ធលើអចលទ្រព្យ | 102,153,0 | 143,123,4 | 40,970,4 | 40.1% |
| | | 70071 | ពន្ធលើអចលនទ្រព្យ(រូបវន្តបុគ្គល) | 92,929,0 | 112,935,0 | 20,006,0 | 21.5% |
| | | 70072 | ពន្ធលើអចលនទ្រព្យ(នីតិបុគ្គល) | 5,130,0 | 16,494,0 | 11,364,0 | 221.5% |
| | | 70073 | ពន្ធលើដីមិនបានប្រើប្រាស់ | 4,094,0 | 13,694,4 | 9,600,41 | 234.5% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងទៀត | 8,623,0 | 20,901,5 | 12,278,5 | 142.5% |
| | | 70081 | ពន្ធតែមប្រ៍ | 8,623.0 | 20,901,5 | 12,278,5 | 142.5% |
| **ប្រភេទទី២ ចំណូលមិនមែនសារពើពន្ធ** | | | | 1,153,256.0 | 1,275,525,0 | 122,269,0 | 10.6% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 14,082,6 | 37,369,8 | 23,287,2 | 165.4% |
| | 7200 | | ផលសម្បទាន | 14,082,6 | 37,369,8 | 23,287,2, | 165.4% |
| | | 72001 | ផលពីនេសាទ | 1,079.0 | 1,196,2 | 117,2 | 10,9% |
| | | 72004 | សម្បទានរ៉ែ | 10,850.2 | 33,948,7 | 23,098,5 | 212,9% |
| | | 72006 | ចំណតយានជំនិះ | 1,768,5 | 1,852,5 | 84,0 | 4.7% |
| | | 72007 | ចំណតជលយាន | 375,4 | 362,9 | -12,5 | -3.3% |
| | | 72008 | ផលសម្បទានផ្សេងៗ | 9,5 | 9,5 | 0,0 | 0.0% |

សម្រាប់ឆ្នាំ២០២២ ចំណូលពន្ធដែលបានមកពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនដែលអនុវត្ត តាមច្បាប់ហិរញ្ញវត្ថុមានចំនួន ៣២៤,៥២៦លានរៀលបើធៀបនឹងឆ្នាំ២០២៣ ដែលមានចំនួន៤១២,៤៩១ លានរៀល គឺមានការកើនឡើងចំនួន ៨៧,៩៦៥លានរៀល ត្រូវជា ២៧.១%។

## ការគ្រប់គ្រងឆ្នាំ២០២៣

## តារាង ក២

ឯកតា:លានរៀល

## ចំណូលថវិការដ្ឋបាលរាជធានីខេត្ត

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ទឹកប្រាក់ | ភាគរយ |
| **សរុបចំណូលថវិការរាជធានី ខេត្ត** | | | | 2,859,652.0 | 3,436,250,0 | 576,598,0 | 20.2% |
| **សរុបចំណូលឆ្លងកាត់តេនាគារជាតិ** | | | | 2,859,652.0 | 3,436,250,0 | 576,598,0 | 20.2% |
| **ក្នុងនោះចំណូលក្នុងប្រទេស** | | | | 2,859,652.0 | 3,436,250,0 | 576,598,0 | 20.2% |
| **ក សរុបចំណូលក្នុងប្រទេស( ក្រ+ក្រ២ )** | | | | 2,859,652.0 | 3,436,250,0 | 576,598,0 | 20.2% |
| **ក្រុមទី១ ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** | | | | 2,859,652.0 | 3,436,250,0 | 576,598,0 | 20.2% |
| **ប្រភេទទី១ ចំណូលសារពើពន្ធ** | | | | **1,584,127.0** | **2,172,350,0** | **588,223,0** | **37,1%** |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 1,584,127.0 | 2,172,350,0 | 533,804,0 | 37,1% |
| | 7001 | | ពន្ធផ្ទាល់( ពន្ធលើផលទុនប្រាក់ចំណូល ) | 281,757.2 | 350,390, | 68,632,8 | 24.4% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | 281,757.2 | 350,390,0 | 68,632,8 | 24.4% |
| | 7003 | | អាករពិសេស | 161,859.2 | 237,880,5 | 75,961,6 | 46.9% |
| | | 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | 161,859.2 | 237,880,5 | 75,961,6 | 46.9% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 2,872.9 | 495,712,0 | 9,007,6 | 313.5% |
| | | 70045 | អាករលើការស្នាក់នៅ | 2,872.9 | 83,221,0 | 9,007,6 | 313.5% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិឬការអនុវត្តសកម្មភាព | 399,321,0 | 412,491,0 | 96,391,0 | 24.1% |
| | | 70053 | ពន្ធប៉ាតង់ | 74,794,0 | 882,091,1 | 8,426,0 | 11.3% |
| | | 70054 | ពន្ធលើមធ្យាបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ | 324.526.0 | 412.491.0 | 87,965,0 | 27.1% |
| | 7006 | | ពន្ធប្រថាប់ត្រា | 574,512,8 | 882.091.1 | 307,799,33 | 53.6% |
| | | 70061 | ពន្ធប្រថាប់ត្រាលើតម្លៃអចលនទ្រព្យចំពោះការផ្ទេរសិទ្ធិឬសិទ្ធិកាន់កាប់ | 560,512,0 | 852.904.4 | 292,392,4 | 52.2% |
| | | 70062 | ពន្ធប្រថាប់ត្រាលើតម្លៃមធ្យោបាយដឹកជញ្ជូលឬយានយន្តចំពោះការផ្ទេរសិទ្ធ | 5,770,3 | 15.133.2 | 9,362,9 | 162.3% |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 70063 | ពន្ធប្រថាប់ត្រាលើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន | 3,558,2 | 5,106,0 | 1,547,8 | 43.5% |
| | | 70064 | ពន្ធប្រថាប់ត្រាលើតម្លៃភាគហ៊ុនចំពោះការផ្គត់ផ្គង់ទំនិញឬសេវា | 3558,2 | 7,757,4 | 4,236,9 | 120.3% |
| | | 70065 | ពន្ធប្រថាប់ត្រាលើលិខិតមានលក្ខណៈគតិយុត្ត | 930,8 | 1,190,1 | 259,3 | 27.9% |
| | 7007 | | ពន្ធលើអចលទ្រព្យ | 143,123,4 | 171.797.9 | 28,674,5, | 20.0% |
| | | 70071 | ពន្ធលើអចលនទ្រព្យ(រូបវន្តបុគ្គល) | 112,935,0 | 138,395,2 | 25,460,2 | 22.5% |
| | | 70072 | ពន្ធលើអចលនទ្រព្យ(នីតិបុគ្គល) | 16,494,0 | 15,697,5 | -796,5 | -4.8% |
| | | 70073 | ពន្ធលើដីមិនបានប្រើប្រាស់ | 13,694,4 | 17,705,2 | 4,010,8 | 29.3% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងទៀត | 20,901,5 | 22,657,7 | 1,756,2 | 8.4% |
| | | 70081 | ពន្ធតែមប្រ៍ | 20,901,5 | 22,657,7 | 1,756,2 | 8.4% |
| **ប្រភេទទី២ ចំណូលមិនមែនសារពើពន្ធ** | | | | **1,275,525,0** | **1,263,900,0** | **-11,625,0** | **-0,9%** |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 37.369.8 | 41,852,2 | 4,482,4 | 12,0% |
| | 7200 | | ផលសម្បទាន | 37.369.8 | 41,852,2 | 4,482,4 | 12.0% |
| | | 72001 | ផលពីនេសាទ | 1.196.2 | 956,3 | -239,9 | -20.1% |
| | | 72004 | សម្បទានរ៉ែ | 33.948.7 | 38,801,1 | 4,852,4 | 14.3% |
| | | 72006 | ចំណតយានជំនិះ | 1.852.5 | 1,752,8 | -99,7 | -5.4% |
| | | 72007 | ចំណតជលយាន | 362.9 | 342,0 | -20,9 | -5,8% |
| | | 72008 | ផលសម្បទានផ្សេងៗ | 9,5 | | -9,5 | -100,0% |
| | | | ផលទុនពីការលក់ជួលទ្រព្យសម្បត្តិនិងសេវា | 207,374,0 | 237,517,4 | 30,143,4 | 14,5% |

**៣.២.៣ ទីកន្លែងបង់ពន្ធ និងការបរិច្ឆេទ**

អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅថ្ងៃទី២៧ ខែឧសភានេះ បានចេញសេចក្តីជូនដំណឹង ដល់ម្ចាស់យានយន្តគ្រប់ប្រភេទលើការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ដែលនឹងត្រូវដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី០១ ខែមិថុនា រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា តទៅ។ ម្ចាស់យានយន្តគ្រប់ប្រភេទត្រូវដាក់លិខិតប្រកាស ឬយកមកជាមួយនូវប័ណ្ណសម្គាល់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ និងធ្វើការបង់ពន្ធនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅធនាគារកាណាឌីយ៉ា ក.អ ឬនៅធនាគារអេស៊ីលីដា ភីអិលស៊ី ឬនៅធនាគារវឌ្ឍនៈ ឬនៅធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី ឬនៅធនាគារជេ ត្រាស់ រ៉ូយ៉ាល់ឬនៅធនាគារស្ថាបនា ភីអិលស៊ីឬនៅធនាគារប្រៃសណីយ៍កម្ពុជា ក.អ ឬនៅធនាគារវឌ្ឍនៈអាស៊ី ចំកាត់ ឬនៅធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ឬនៅតាមធនាគារដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអាចបង់តាមរយៈកម្មវិធី«GDT Taxpayer App» ដែលអាចទាញយកចេញពី App Store ចំពោះ iOS ឬPlay Store ចំពោះ Android សម្រាប់យានយន្តដែលធ្លាប់បានប្រកាសបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទកន្លងមក។ ដោយឡែក យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូត ឬស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបាននូវលតាបត្របង់ពន្ធ (ពន្ធជាបន្ទុករបស់រដ្ឋ)។ ចំពោះយានយន្តរបស់ក្រសួង-ស្ថាប័ន ឬអង្គភាពដែលត្រូវទទួលបានលតាបត្រពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ ( ពន្ធជាបន្ទុករបស់រដ្ឋ ឬបង់តាមអាណត្តិបើកប្រាក់) ត្រូវភ្ជាប់មកជាមួយនូវបញ្ជីសារពើភ័ណ្ឌយានយន្តទ្រព្យសម្បត្តិរដ្ឋ (តារាងកើនឡើង និងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ) ដែលបានចុះបញ្ជីនៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អគ្គនាយកដ្ឋានពន្ធដារបានគូសបញ្ជាក់ទៀតថា ចំពោះយានយន្តឯកជនជ្រកក្រោមផ្លាកលេខ រដ្ឋ ផ្លាកលេខ ខ.ម និង ន.ប ពុំអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទទេ។ ម្ចាស់យានយន្តទាំងនេះអាចបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ បានលុះត្រាតែបំពេញកាតព្វកិច្ចពន្ធ និងអាករនាំចូលស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីគយ និងចុះបញ្ជីយានយន្តនៅក្រសួងសាធារណការនិងដឹកជញ្ជូន ឱ្យបានរួចរាល់ជាមុនសិន។ អគ្គនាយកដ្ឋានពន្ធដារនឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចដើម្បីចុះត្រួតពិនិត្យការប្រកាសបង់ពន្ធ និងធ្វើការពិន័យចំពោះម្ចាស់យានយន្តទាំងឡាយណាដែលមិនទាន់បានប្រកាសបង់ពន្ធ ក្នុងឆ្នាំកន្លងមក តាមច្បាប់ស្តីពីសារពើពន្ធជាធរមាន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំបន្ទាប់តទៅ។







រូបភាពបង់ពន្ធដោយផ្ទាល់

# របៀបបង់ពន្ធតាមរយៈកម្មវិធីរបស់អគ្គនាយកដ្ឋានពន្ធដារ






















៨


៩


១០


១១


១២


១៣
ចុច ជ្រើសរើស
យានយន្តដែលចង់បង់ពន្ធ


ករណីមិនទាន់មានប័ណ្ណសម្គាល់ការបង់ពន្ធ
កម្មវិធីនឹងកំណត់ឱ្យជ្រើសយក
ប័ណ្ណសម្គាល់ជា eCard ដោយស្វ័យប្រវត្តិ
១៤


១៥
ជ្រើសរើសធនាគារ
ណាមួយដើម្បីបង់ប្រាក់ពន្ធ


១៦


១៧
2023
250,000 ៛

### ៣.២.៤ ការផាកពិន័យលើការខកខានមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន

មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទដែលខកខានឬមិនបានទៅបង់ពន្ធមធ្យោបាយដឹកសម្រាប់បណ្ដាឆ្នាំកន្លងមកត្រូវបង់ប្រាក់ពន្ធនិងប្រាក់ពិន័យឱ្យរួចរាល់ជាមុនសិន ទើបអនុញ្ញាតឱ្យបង់ពន្ធសម្រាប់ឆ្នាំបច្ចុប្បន្ន។ ប្រាក់ដែលត្រូវផាកពិន័យស្មើនឹង១០០% នៃប្រាក់ពន្ធត្រូវបង់។ ម្ចាស់យានជំនិះគ្រប់ប្រភេទ ដែលជាប់កាតព្វកិច្ចបង់ពន្ធជូនរដ្ឋ ហើយខកខានមិនបានបង់ពន្ធប្រចាំឆ្នាំ តាមកាលកំណត់របស់អគ្គនាយកដ្ឋានពន្ធដារត្រូវប្រឈមនិងការចាប់ផាកពិន័យទ្វេគុណលើតម្លៃពន្ធធម្មតា។

ម្ចាស់យានយន្តដែលខកខានមិនបានបង់ពន្ធទាន់ពេលវេលាកំណត់ខាងលើ នឹងត្រូវទទួលរងទោសទណ្ឌទៅតាមច្បាប់ស្ដីពីសារពើពន្ធជាធរមាន បន្ទាប់ពីថ្ងៃបិទបញ្ចប់ការប្រមូលពន្ធនេះអគ្គនាយកដ្ឋានពន្ធដារនឹងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះត្រួតពិនិត្យការប្រមូលពន្ធនេះនៅតាមដងផ្លូវនានា។

## ៣.៣ អត្ថប្រយោជន៍នៃចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូន ចំពោះប្រទេសជាតិ

បច្ចុប្បន្ននេះយើងសង្កេតឃើញថា ពន្ធមានច្រើនប្រភេទនៅក្នុងប្រទេសកម្ពុជាដូចជា ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន អាករលើតម្លៃបន្ថែម ពន្ធលើប្រាក់បៀវត្ស ពន្ធលើប្រាក់ចំណូល ពន្ធកាត់ទុក និងពន្ធអចលនទ្រព្យជាដើម ។ ការបង់ពន្ធនេះគឺជាកាតព្វកិច្ចរបស់យើងគ្រប់ៗគ្នាក្នុងនាមជាពលរដ្ឋដែលរស់នៅក្នុងប្រទេសនីមួយៗ មិនថាតែនៅក្នុងប្រទេសកម្ពុជាឡើយគ្រប់បណ្ដាលប្រទេសទាំងអស់ ការបង់ពន្ធនេះមានតាំងពីយូរយារណាស់មកហើយគឺចាប់តាំងពីការបង្កើតរដ្ឋដំបូងមកម្ល៉េះជាក់ស្តែងដូចជាប្រទេសកម្ពុជា ជាប្រទេសមួយដែលកំពុងអភិវឌ្ឍ និងរីកចម្រើនស្ទើរគ្រប់វិស័យនៅតំបន់អាស៊ីអាគ្នេយ៍ដែលជាហេតុធ្វើឱ្យប្រទេសជាតិមានចំណាយកើនឡើងខ្ពស់។

ប្រភពប្រាក់ចំណូលប្រទេសជាតិមាន២ធំៗគឺ ចំណូលចរន្ត(ចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធ) និងចំណូលមូលធន គឺបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងប្រទេសជាតិឱ្យប្រកបដោយចីរភាពទន្ទឹមនិងនេះដើម្បីបានប្រភពប្រាក់ចំណូលយកទៅទប់ទល់និងចំណាយដោយមិនចាំបាច់បោះពុម្ពលុយ ដែលជាហេតុអាចបង្កឱ្យមានអតិផរណាសម្រាប់ប្រទេសកម្ពុជា ក្នុងនោះដែរអគ្គនាយកដ្ឋានពន្ធដារ ក៏បានដើរតួយ៉ាងសំខាន់ក្នុងការប្រមូលពន្ធពីគ្រប់មជ្ឈដ្ឋាននិងអ្នកជាប់ពន្ធទាំងអស់។ ដើម្បីឱ្យការប្រមូលពន្ធនេះប្រកបដោយប្រសិទ្ធភាពក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្កើតច្បាប់ស្ដីពីសារពើពន្ធ ដាក់ឱ្យប្រជាពលរដ្ឋប្រើប្រាស់រួមទាំងសហគ្រាស ស្ថាប័នរដ្ឋ និងឯកជន នឹងអង្គការមិនស្វែងរកប្រាក់ចំណេញជាដើម ដើម្បីចូលរួមចំណែកគ្នាក្នុងការបង់ពន្ធជូនរដ្ឋ ។ ការបង្កើនប្រាក់ចំណូលបន្ថែម និងជួយទ្រទ្រង់ចំណាយធំៗជាច្រើនរបស់ជាតិរួមមានដូចខាងក្រោម៖




ចំណាយចរន្តថវិកាថ្នាក់ជាតិត្រូវតាមបានវិភាជតាមវិស័យ គ្រប់ដណ្តប់លើក្រសួងស្ថាប័នទាំង៣៩ ហើយនៅកម្រិតក្រសួង-ស្ថាប័ននីមួយៗវិញត្រូវបានធ្វើការវិភាគបន្តទៅតាមកម្មវិធីអនុវត្តកម្មវិធី រហូតដល់ចង្កោមសកម្មភាព តាមរយៈការឆ្លុះបញ្ចាំងយ៉ាងលម្អិតទៅតាមមាតិកាសេដ្ឋកិច្ចនៃចំណាត់ថ្នាក់ថវិកា ដោយផ្អែកលើតម្រូវការនិងអាទិភាពចាំបាច់ដូចតទៅៈ

**<u>វិស័យរដ្ឋបាលទូទៅ</u>**

- គាំទ្រដល់**ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៧**
- គាំទ្រដល់ការធ្វើជា**ម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី ៣២ និង អាស៊ានប៉ារ៉ាហ្គេមលើក ទី ១២ ឆ្នាំ ២០២៣**
- បន្តគាំទ្រដល់សកម្មភាពបោសសម្អាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ឆ្ពោះទៅរកកម្ពុជាគ្មានគ្រាប់មីននៅឆ្នាំ ២០២៥ ក្រោមទិសស្លោក **ផ្តល់ដីសុវត្ថិភាព បង្កើតស្នាមញញឹម**
- បន្តគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពការងារគ្រប់គ្រងចំណូល និងប្រមូលចំណូលសារពើពន្ធ
- រៀបចំ និងអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុមិនមែនធនាគារ
- បន្តគាំទ្រដល់ធុរៈកិច្ចថ្មី សហគ្រិនភាពផ្ទាល់ខ្លួនឌីជីថល និងសេដ្ឋកិច្ចនវានុវត្តន៍
- បន្តគាំទ្រដល់ការអនុវត្តការងារនិងតួនាទីរបស់ស្ថាប័ននីតិប្បញ្ញត្តិ

- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- គាំទ្រដល់ការពង្រឹងការគ្រប់គ្រងវិស័យសំណង់ ការរៀបចំប្លង់គោល និងនគរូបនីយកម្ម
- បន្តគាំទ្រកំណែទម្រង់វិស័យដីធ្លី
- បន្តគាំទ្រ និងពង្រឹងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មឆ្នាំ ២០១៥-២០២៥
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ
- បន្តគាំទ្រដល់ការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចការទូត
- បន្តគាំទ្រដល់ការចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ។

**<u>វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់</u>**

- បន្តគាំទ្រដល់ការពង្រឹងសមត្ថភាពរបស់នគរបាល និងកងកម្លាំងប្រដាប់អាវុធ
- បន្តផ្តោតការយកចិត្តទុកដាក់លើជីវភាព និងសុខុមាលភាពកងកម្លាំងប្រដាប់អាវុធ
- បន្តគាំទ្រដល់កិច្ចដំណើរការរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សាលាជម្រះក្តីគ្រប់ ជាន់ថ្នាក់ និងរដ្ឋបាលតុលាការ
- បន្តគាំទ្រកិច្ចដំណើរការរដ្ឋបាល និងអន្តរាគមន៍ផ្សេងៗ
- បន្តគាំទ្រដល់ដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បន្តគាំទ្រការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព
- បន្តគាំទ្រដល់ប្រព័ន្ធត្រួតពិនិត្យសន្តិសុខតាមច្រកព្រំដែន និងការផលិតលិខិតឆ្លងដែន
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ស្ត្រី និងកុមារ
- បន្តគាំទ្រដល់កិច្ចការសន្តិសុខជាតិ សកម្មភាពការងារកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងការប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បន្តគាំទ្រសេវាឥតគិតថ្លៃរបស់គណៈមេធាវីកម្ពុជា។

**<u>វិស័យសង្គមកិច្ច</u>**

- **បន្តគ្រប់គ្រងឱ្យបាននូវការរីករាលដាលនៃជំងឺកូវីដ-១៩**
- បន្តគាំទ្រដល់ការលើកកម្ពស់គុណភាព និងការទទួលបានសេវាសុខាភិបាល
- បន្តគាំទ្រដល់ការពង្រឹងនិងពង្រីកការទទួលបានសេវាអប់រំ និងការលើកកម្ពស់គុណភាពអប់រំ
- បន្តគាំទ្រដល់ការលើកកម្ពស់វិស័យកីឡាជាតិ
- បន្តគាំទ្រដល់ការអភិវឌ្ឍជំនាញ និងវិស័យការងារ
- បន្តផ្តល់របបសន្តិសុខសង្គមរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន
- បន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ
- បន្តគាំទ្រដល់ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ

- បន្តឧបត្ថម្ភគាំទ្រដល់សមាគមន៍អតីតយុទ្ធជន
- បន្តឧបត្ថម្ភដល់មជ្ឈមណ្ឌលស្តារនីតិសម្បទាតាមបណ្តារាជធានី-ខេត្ត និង មជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្ម កាយសម្បទា
- បន្តផ្តល់ថវិកាគាំទ្រដល់ការដោះស្រាយជីវភាពចំពោះជនក្រីក្រ និងចាស់ជរានៅតាម សហគមន៍
- បន្តគាំទ្រដល់ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ
- បន្តគាំទ្រដល់ការការពារ និងអភិរក្សធនធានធម្មជាតិ
- បន្តគាំទ្រដល់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ជាតិ
- បន្តគាំទ្រដល់សុខដុមនីយកម្មសាសនា។

<u>**វិស័យសេដ្ឋកិច្ច**</u>

- បន្តគាំទ្រដល់ការលើកកម្ពស់បច្ចេកទេសកសិកម្ម និង សុវត្ថិភាពចំណីអាហារ
- បន្តគាំទ្រដល់ការគ្រប់គ្រងដីសម្បទានសេដ្ឋកិច្ច, ការបង្ការទប់ស្កាត់, និងបង្ក្រាបបទល្មើសព្រៃឈើ និងជលផល
- បន្តគាំទ្រដល់ការពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រងធនធានរ៉ែគ្រប់ប្រភេទ
- បន្តគាំទ្រដល់ការអភិវឌ្ឍទឹកស្អាត និងអនាម័យជនបទ
- បន្តគាំទ្រដល់ការជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រ
- ជំរុញការអភិវឌ្ឍផលិតផល និងការពង្រឹងគុណភាពសេវាទេសចរណ៍
- ការស្តារព្រៃឈើឡើងវិញ និងសង្គ្រោះសត្វព្រៃ
- បន្តបើកទីផ្សារសម្រាប់ការនាំចេញរបស់កម្ពុជា
- បន្តគាំទ្រដល់ការជួសជុល ថែទាំផ្លូវ ស្ពាន និងផ្លូវលំជនបទ ព្រមទាំងការស្តារស្រះ ជីកស្រះ និងអណ្តូងទឹក ដើម្បីទប់ទល់នឹងគ្រោះរាំងស្ងួត
- បន្តគាំទ្រដល់ការត្រួតពិនិត្យសុវត្ថិភាពចំណីអាហារ
- បន្តគាំទ្រដល់ការអភិវឌ្ឍវិស័យទូរគមនាគមន៍
- បន្តគាំទ្រដល់ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម។

**ព័ត៌មានបន្ថែមសម្រាប់ទំហំចំណាយថវិកាសរុប (ចំណាយចរន្ត និងចំណាយមូលធន ក្នុងប្រទេស និងក្រៅប្រទេស) របស់ក្រសួង ស្ថាប័ន មានក្នុង<u>តារាងឧបសម្ព័ន្ធទី ៣៩</u>**

លើសពីនេះ សម្រាប់ឆ្នាំ២០២៣ រាជរដ្ឋាភិបាលក៏បានគ្រោងថវិកា ឆ្លើយតបនឹងសកម្មភាពគាំពារសង្គមដែលរួមមានជាអាទិ៍ដូចជា៖

- ❖ **ការបន្តគាំទ្រការថែទាំសុខភាពសម្រាប់កម្មករ៖**

បានត្រៀមថវិកាក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល

សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ( ទាំងក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធ )ដែលមិនទាន់ជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស.)ទទួលបាន របបថៃទាំសុខភាពដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ

- **ការបន្តការឧបត្ថម្ភមាតុភាពសម្រាប់កម្មករនិយោជិតៈ** បានគ្រោងនៅក្នុងកញ្ចប់ថវិកា របស់ក្រសួងសុខាភិបាលសម្រាប់បន្តបើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនី នៅក្រោយ ពេល សម្រាលកូន និងសម្រាកលំហែមាតុភាព
- **ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផាៈ** បន្តផ្តល់ថវិកាសម្រាប់បង្កើន "មូលនិធិគន្ធបុប្ផាកម្ពុជា" បន្ថែមលើថវិកាដែលត្រូវផ្តល់ផ្ទាល់ទៅមន្ទីរពេទ្យគន្ធបុប្ផាសម្រាប់ចំណាយ ប្រតិបត្តិការឆ្នាំ ២០២៣, ដើម្បីធានានិរន្តរភាព គុណភាព និងប្រសិទ្ធភាព របស់ មន្ទីរពេទ្យផង និងធានា ការផ្តល់សេវាដោយមិនយកថ្លៃជូនដល់កុមារនៃគ្រួសារ ក្រីក្រផង
- **កម្មវិធីផ្ទេរសាច់ប្រាក់សម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និងកុមារតូចៈ** បានគ្រោងថវិកាសម្រាប់ ឧបត្ថម្ភពេលពិនិត្យផ្ទៃពោះចំនួន ៤ លើក, ១ លើក ៤ ម៉ឺនរៀល, ពេលសម្រាលកូននៅ មណ្ឌលសុខភាព ឬពេទ្យរដ្ឋជូន ២០ម៉ឺនរៀល, ឧបត្ថម្ភ ១០ លើកទៀត ១លើក ៤ ម៉ឺន រៀល ពេលទៅទទួលថ្នាំបង្ការរហូតដល់កុមារអាយុ ២ ឆ្នាំ។

**-<u>ចំណាយមូលធនថ្នាក់ជាតិ</u>**

ត្រូវបានគ្រោងចំនួន **១៥,៧៦៤,២៧៣ លានរៀល**, មានសមាមាត្រ ស្មើនឹង **៤៣,១%** នៃ ចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា ១២,០១% នៃ ផសស, មានកំណើន ១៧,១% ធៀបនឹង ច្បាប់ថវិកាឆ្នាំ២០២២,**ក្នុងគោលដៅគាំទ្រដល់ការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល** (២០២៣-២០២៥) ជាពិសេសការអនុវត្ត "**យុទ្ធសាស្ត្រស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុង ការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី**" ។ គម្រោងវិនិយោគសាធារណៈ **ដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ** ត្រូវបានគ្រោងចំនួន **៧,៧៣០,៩៧១ លានរៀល**, ត្រូវជា **៥,៨៩**% នៃ ផសស, កើនឡើង **២៥,២%** ធៀបនឹងច្បាប់ថវិកាឆ្នាំ ២០២២ ដោយផ្តោត អាទិភាពទៅលើ÷

- **ការបន្តអន្តរាគមន៍ទប់ទល់នឹងផលប៉ះពាល់ពីជំងឺកូវីដ-១៩** និង **សម្គាធអតិផរណា**មានដូច ជា÷
  - ✓ កម្មវិធីឧបត្ថម្ភសាច់ប្រាក់ដល់គ្រួសារក្រីក្រ (ក្រ១, ក្រ២) និងជនងាយរងគ្រោះ និង កញ្ចប់ឧបត្ថម្ភគ្រួសារ ត្រូវបានគ្រោងថវិកាចំនួន ១,៦២៦ ប៊ីលានរៀល, សមមូល នឹង ប្រមាណ ៤០០ លានដុល្លារអាម៉េរិក សម្រាប់រយៈពេល ១២ ខែ
  - ✓ កម្មវិធីឧបត្ថម្ភសាច់ប្រាក់មួយគ្រាជូនគ្រួសារដែលងាយរងហានិភ័យ (គ្រួសារដែល មាន ជីវភាពកៀកនឹងបន្ទាត់នៃភាពក្រីក្រ) ចំនួន ២៦៤,២ ប៊ីលានរៀល, សមមូល នឹង ប្រមាណ ៦៥ លានដុល្លារអាម៉េរិក

- ✓ កម្មវិធីបណ្តុះបណ្តាលសមត្ថភាពជំនាញវិជ្ជាជីវៈ និងការជួយកម្មករព្យួរកិច្ចការងារ ត្រូវបានគ្រោងថវិកាចំនួន ២៤៣,៩ ប៊ីលានរៀល, សមមូលនឹងប្រមាណ ៦០ លានដុល្លារអាមេរិក
- ✓ គម្រោងសាច់ប្រាក់ពលកម្ម (Cash for Works) ត្រូវបានគ្រោងថវិកាចំនួន ៤០៦.៥ ប៊ីលានរៀល, សមមូលនឹងប្រមាណ ១០០ លានដុល្លារអាម៉េរិក, សម្រាប់បង្កើត ការងារ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តនៅជនបទ រួមមាន ប្រឡាយជើងក្លែម ស្រះទឹក អណ្តូង និងបង្គន់អនាម័យនៅតាមសាលារៀនជាដើម
- ✓ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍរុនតាឯក និងតំបន់អភិវឌ្ឍ ពាក់ស្នែង ខេត្តសៀមរាប ចំនួន ១០០ ប៊ីលានរៀល, សមមូលស្មើនឹងប្រមាណ ២៥ លានដុល្លារអាម៉េរិក
- ✓ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងបៃតងត្រូវបានគ្រោងថវិកាចំនួន ២០៣.៣ ប៊ីលានរៀល, សមមូលនឹងប្រមាណ ៥០ លានដុល្លារអាមេរិក
- ✓ ការអនុវត្តយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនចំនួន ៤០៦.៥ ប៊ីលានរៀល, សមមូលនឹងប្រមាណ ១០០ លានដុល្លារអាម៉េរិក
- ✓ ឧបករណ៍ផ្តល់ហិរញ្ញប្បទានបន្ថែមដល់សហគ្រាសធុនតូច និងមធ្យមចំនួន ៤០៦.៥ ប៊ីលានរៀល, សមមូលនឹងប្រមាណ ១០០ លានដុល្លារអាម៉េរិក;
- ✓ ការជំរុញពិពិធកម្មសេដ្ឋកិច្ច និងភាពប្រកួតប្រជែងចំនួន ១២២ ប៊ីលានរៀល, សមមូលនឹងប្រមាណ ៣០ លានដុល្លារអាម៉េរិក។

- ❖ ការកសាង និងជួសជុលហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ស្ពាន លូ ជាពិសេសការជួសជុល ឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលរងផលប៉ះពាល់ពីជំនន់ទឹកភ្លៀង រួមទាំងការកសាង ប្រព័ន្ធចម្រោះទឹកកខ្វក់ ប្រព័ន្ធលូ អូរ ប្រឡាយរំដោះទឹកភ្លៀង និងប្រព័ន្ធបង្ហូរទឹកកខ្វក់
- ❖ ការបន្តស្តារនិងកសាងប្រព័ន្ធធារាសាស្ត្រ និងលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងធារាសាស្ត្រ
- ❖ ការជំរុញផលិតកម្មស្បៀង និងការលើកកម្ពស់ផលិតភាពកសិកម្ម
- ❖ ការបន្តកសាងហេដ្ឋារចនាសម្ព័ន្ធវិស័យអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធចាំបាច់មួយចំនួនផ្សេងទៀត ។

# ជំពូកទី៤

# ការវិភាគលើចំណុចខ្លាំង និង ចំណុចខ្សោយ

ជាការពិតណាស់ ការវិភាគលើចំណុចខ្លាំងនិងចំណុចខ្សោយលើការអនុវត្តការងារ ឬច្បាប់ដែលបានកំណត់តែងតែមាន។ ការវាយតម្លៃវាមានសារៈសំខាន់ណាស់ដើម្បីអោយយើងដឹងពីចំណុចខ្លាំងនឹងចំណុចខ្សោយ សម្រាប់យកកែតម្រូវដើម្បីអោយមានភាពច្បាស់លាស់បន្ថែមទៀតក្នុងការគ្រប់គ្រង និងការអនុវត្តជាក់ស្តែង។ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ កន្លងមកចំពោះប្រធានបទស្តីពី "**ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ**" ក្រុមយើងខ្ញុំបានរកឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយមួយចំនួនដូចជា៖

## ៤.១ ការវិភាគលើចំណុចខ្លាំង

- អគ្គនាយកដ្ឋានពន្ធដារពិតជាដើរតួយ៉ាងសំខាន់ក្នុងការប្រមូលថវិការចូលជាតិ យើងសង្កេតឃើញថាពីមួយឆ្នាំទៅមួយកំណើននៃប្រាក់ចំណូលពីការប្រមូលពន្ធមធ្យោបាយដឹកជញ្ជូន គឺមានការកើនឡើងជាលំដាប់បើធៀបពីមួយឆ្នាំទៅមួយឆ្នាំ នេះគឺដោយសារការខិតខំប្រឹងប្រែងនិងយកចិត្តទុកដាក់របស់អគ្គនាយកដ្ឋានពន្ធដារ
- អ្នកជាប់ពន្ធមានការយល់ដឹងច្រើនអំពីកាតព្វកិច្ចក្នុងការបង់ពន្ធ
- ប្រាក់ចំណូលដែលបានប្រមូលបានមកពីការបង់ពន្ធ គឺបានចូលរួមចំណែកយ៉ាងច្រើនក្នុងការអភិវឌ្ឍសង្គមជាតិ។
- អគ្គនាយកដ្ឋានពន្ធដារបានបង្កើត GDT Taxpayer Appបន្ថែមមួយទៀត ដែលជួយសម្រួលដល់អ្នកជាប់ពន្ធដើម្បីងាយស្រួលនិងមានភាពឆាប់រហ័ស ក្នុងការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនដោយមិនចំបាច់ចំណាយពេលវេលាច្រើន
- អគ្គនាយកដ្ឋានពន្ធដារ មានអ្នកដឹកនាំប្រកបដោយសមត្ថភាព និងមានបុគ្គលិកលក្ខណៈពោរពេញទៅដោយបទពិសោធន៍ និងមានជំនាញក្នុងការដឹកនាំយ៉ាងមានប្រសិទ្ធិភាព។
- អគ្គនាយកដ្ឋានពន្ធដារ មានការរឹតបណ្តឹង និងធ្វើការផាកពិន័យទៅលើអ្នកជាប់ពន្ធដែលមិនបានធ្វើការបង់ពន្ធត្រឹមត្រូវ និងទាន់ពេលកំណត់ដោយច្បាប់នៅតាមដងផ្លូវ ដើម្បីជានាគុណប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិ។

## ៤.២ ការវិភាគលើចំណុចខ្សោយ

ក្រោយពីបានរកឃើញនូវចំណុចខ្លាំងខាងលើមក ពួកខ្ញុំក៏បានឃើញនូវចំណុចខ្សោយមួយចំនួនដែលបានផ្តល់ផលប៉ះពាល់ដល់ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនមួយចំនួនដូចខាងក្រោម៖

- ទោះបីជាអគ្គនាយកដ្ឋានពន្ធដារ បានខិតខំរឹតបណ្តឹង និងទប់ស្កាត់ទៅលើការគេចវេសបង់ពន្ធយ៉ាងណាក៏ដោយ ក៏នៅមានចំណុចធ្វេសប្រហែសមួយចំនួនដូចជា ការគេចវេសមិនព្រមបង់ពន្ធ ការពន្យាការបង់ពន្ធ និងការបង់ពន្ធមិនត្រឹមត្រូវស្របតាមច្បាប់កំណត់របស់អ្នកជាប់ពន្ធមួយចំនួនតូចដែលមិនទាន់យល់ដឹងអំពីច្បាប់ពន្ធ ។

- ការបង់ពន្ធតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម(App) ទើបតែបង្កើតថ្មីទើបធ្វើឱ្យមានការអាក់រអួលនិងមានភាពស្មុកស្មាញខ្លះចំពោះអ្នកជាប់ពន្ធមួយចំនួន ពីព្រោះពួកគាត់នៅមិនទាន់យល់ច្បាស់ពីការដំណើរការរបស់វាច្បាស់នៅឡើយ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

ក្នុងនាមយើងខ្ញុំជាក្រុមនិស្សិតដែលបានធ្វើការស្រាវជ្រាវអំពី ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន បានមើលឃើញថាពន្ធលើមធ្យោបាយដឹកជញ្ជូននេះ គឺជាប្រភេទពន្ធមួយក្នុងប្រភេទពន្ធជាច្រើនទៀត ដែលពិតជាមានសារៈសំខាន់ណាស់ក្នុងការកៀរគរចំណូលដែលជា ប្រយោជន៍ដល់ថវិកាជាតិ។ ដូច្នេះហើយក្នុងនាមយើងជាប្រជាពលរដ្ឋទាំងអស់ ដែលមានការជាប់ពន្ធត្រូវមានកាតព្វកិច្ចបង់ពន្ធដោយស្ម័គ្រចិត្ត និងស្មោះត្រង់ឱ្យទាន់ពេលវេលា និងចូលរួមសហការជាមួយនឹងរដ្ឋបាលសារពើពន្ធក្នុងការអនុវត្តន៍ច្បាប់និងបទប្បញ្ញត្តិផ្សេងៗស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនឱ្យមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់។ ទោះបីយ៉ាងណាបញ្ហាអ្នកបង់ពន្ធយឺត និងអ្នកគេច វេសក្នុងការបង់ពន្ធក៏ជាបញ្ហាកង្វល់មួយរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលពិបាកក្នុងការគ្រប់គ្រង និងប្រមូលពន្ធឱ្យទាន់ពេលវេលាដែលបានកំណត់ និងមានប្រសិទ្ធភាពខ្ពស់ផងដែ បច្ចុប្បន្ននេះ យើងឃើញថាអគ្គនាយកដ្ឋានពន្ធដារបានប្រែមុខមាត់ថ្មី មានភាពទំនើបកម្មជាងមុន ដោយមានការគ្រប់គ្រងប្រព័ន្ធទិន្នន័យរឹងមាំ ការផ្តត់ផ្គង់សេវាមានភាពឆាប់រហ័ស មានប្រសិទ្ធភាពខ្ពស់ជាងមុន និងផ្តល់ភាពងាយស្រួល ដល់អ្នកជាប់ពន្ធជាច្រើនដូចជា ការបង្កើតប្រព័ន្ធព័ត៌មានទាក់ទងនឹងពន្ធដារ កាន់តែមានភាពទូលំទូលាយ ការប្រកាសពន្ធមានលក្ខណៈទំនើប អាចធ្វើការប្រកាសតាមប្រព័ន្ធអ៊ីនធើណេតបាន កន្លែងបង់ពន្ធមានដាក់នូវប្រព័ន្ធចាប់លេខដែលផ្តល់ភាពងាយស្រួល និងប្រកបដោយយុត្តិធម៌ចំពោះប្រជាជន ជាប់ពន្ធគ្រប់រូប។

ក្នុងនេះផងដែរផ្អែកលើសមិទ្ធផលសម្រេចបាន សក្តានុពលដ៏ធំធេងនៃព្រះរាជាណាចក្រកម្ពុជា ឆន្ទៈដ៏មុះមុត និងទេពកោសល្យរបស់ប្រជាជនកម្ពុជា ព្រមទាំងកែតម្រឹម ការបន្សុំ និងយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាព រាជរដ្ឋាភិបាលបានកំណត់គោលដៅឱ្យប្រទេសកម្ពុជា ប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។ រាជរដ្ឋាភិបាលក៏នៅតែបន្តរិះរកគោលការណ៍ និងយុទ្ធសាស្ត្រថ្មីៗ ដើម្បីធ្វើយ៉ាងណាឱ្យការកើនឡើងនូវការប្រមូលចំណូលនេះ នៅតែបន្តជារៀងដរាបតរៀងទៅ ហើយវាក៏បានសបញ្ជាក់ឱ្យឃើញថាសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាមានវឌ្ឍនភាព ដូច្នេះជីវភាពរបស់ប្រជាជនកាន់តែមានភាពល្អ ប្រសើរជាងមុនផងដែរ។ បំណុលពន្ធទៀតសោត អគ្គនាយកដ្ឋានពន្ធដារ ធ្វើបានកាន់តែល្អប្រសើរចំពោះការប្រមូលពន្ធនេះ ដែលនីតិវិធីមានប្រសិទ្ធភាពខ្ពស់ជាងមុន។

ជារួមមក ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន នៅកម្ពុជាមានការផ្លាស់ប្តូរច្រើន និងរីកចម្រើនគួរឱ្យកត់សម្គាល់ពីតំណាក់កាលមួយទៅតំណាក់កាលមួយ និងមានការកែសម្រួល ដែលបង្កភាពងាយស្រួលមួយចំនួនដល់ការបង់ពន្ធ និងកត្តាផ្សេងទៀតដែលបានលើកឡើង។

## ៥.២ ការផ្តល់អនុសាសន៍

យោងតាមរយៈការសិក្សាស្រាវជ្រាវលំអិតជាលទ្ធផលយើងខ្ញុំសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារបានរៀបចំយុទ្ធសាស្ត្រ កៀរគរចំណូលយ៉ាងមានប្រសិទ្ធិភាព ទាំងតាមរយៈការបជ្រៀបចំណេះដឹង និង

ផ្តល់ភាព ងាយស្រួលដល់អ្នកជាប់ពន្ធតាមរយៈការវិវត្តនូវបច្ចេកវិទ្យាថ្មីភ្ជាប់នៅលើគេហទំព័ររបស់អគ្គនាយកដ្ឋានពន្ធដារ។ ក្រុមយើងខ្ញុំសូមគាំទ្រ និងលើកទឹកចិត្តដល់ខាងអគ្គនាយកដ្ឋានពន្ធដារ ក្នុងការបន្តនូវបេសកកម្មរបស់ខ្លួនក្នុងការ អភិវឌ្ឍបច្ចេកវិទ្យា និងពង្រឹងនីតិវិធីឱ្យកាន់តែមានភាពប្រសើរឡើងថែមទៀត។ ទន្ទឹមនិងនេះផងដែរ ខាងអគ្គនាយកដ្ឋានពន្ធដារគួរកែលំអរនូវចំណុចខ្វះខាតដូចខាងក្រោម៖

- អគ្គនាយកដ្ឋានពន្ធដារគួរតែផ្សព្វផ្សាយ និងបង្ហោះសារក៏ដូចជាព័ត៌មានផ្សេងៗ អំពីដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន ឱ្យបានកាន់តែទូលំទូលាយនៅលើបណ្តាញសង្គមឬវេបផ្សាយផ្សេងៗមិនមែនគ្រាន់តែបង្ហាញនូវសេចក្តីប្រកាសមួយសន្លឹកនោះទេ។
- អគ្គនាយកដ្ឋានពន្ធដាត្រូវការផ្សព្វផ្សាយអំពីច្បាប់ពន្ធដាដល់ប្រជាពលរដ្ឋអោយមានយល់ដឹងអំពើការយល់ អំពីភាពសំខាន់នៃការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន។
- អគ្គនាយកដ្ឋានពន្ធដាត្រូវរឹតបន្តឹងទៅលើប្រព័ន្ធបច្ចេកវិទ្យាបន្ថែមទៅទៀត ជាពិសេសប្រព័ន្ធប្រើប្រាស់អេឡិចត្រូនិកក្នុងការបង់ពន្ធ ឬចុះបញ្ជីមធ្យោបាយដឹកជញ្ជូនអោយស្មើរនឹងបណ្តាលប្រទេសអភិវឌ្ឍផ្សេងៗទៀត។
- អគ្គនាយកដ្ឋានពន្ធដាត្រូវមានសមត្ថភាពគ្រប់គ្រងទិន្នន័យការប្រមូល និងគ្រប់គ្រងទិន្នន័យជាក់លាក់អំពីពន្ធលើមធ្យោបាយដឹកជញ្ជូនអោយមានប្រសិទ្ធភាព ។

# ឯកសារយោង


- ប្រកាស៧៣៨ ស្ដីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ ២០២៤ លេខ១៩៦ អន-ក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤
- កិច្ចការស្រាវជ្រាវ ស្ដីពីដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ ជំនាន់២០( ពួយ សុលីនដា,ម៉ៅ ស៊ីម៉ាច,សុខន ស្រីពៅ,..)
- អគ្គនាយកដ្ឋានពន្ធដារ. សំណួរនិងចម្លើយ. Retrieved June, 23 2025 from https://www.tax.gov.kh/km/faq#
- កិច្ចការស្រាវជ្រាវ ស្ដីពីពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ ដោយក្រុម៖ ពេជ្រ មេសា,ថាម ណាថេប,អ៊ួង ឧត្តម,...ឆ្នាំសិក្សា ២០១៨-២០១៩
- ស្លាយបទបង្ហាញស្ដីពីពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានយន្តគ្រប់ប្រភេទ របស់សាលាជាតិពន្ធដារ
- ម៉ាយខាអ៊ីមផត. (សេវាដឹកជញ្ជូនផ្លូវអាកាស). Retrieved June, 23 2025 from https://km.mycarimport.co.uk/kb/what-is-air-freight/
- ក្រសួងសាធារណៈការ និងដឹកជញ្ជូន.(សេវាដឹកជញ្ជូនផ្លូវទឹក). Retrieved June, 23 2025 from https://www.mpwt.gov.kh/kh/public-services/water-taxi
- វេបសាយ ក្រសួងសាធារណៈការ និងដឹកជញ្ជូន (សេវាដឹកជញ្ជូនផ្លូវដែក). Retrieved June, 23 2025 from https://www.mpwt.gov.kh/kh/public-services/railway-services
- ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងតាមឆ្នាំ និងថវិកាសង្ខេបឆ្នាំ២០២២
- ច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងតាមឆ្នាំ និងថវិកាសង្ខេបឆ្នាំ២០២៣
- ថវិកាសង្ខេបឆ្នាំ២០២៣ (នាយកដ្ឋានថវិកានីយកម្ម អគ្គនាយកដ្ឋានថវិកា)

# ឧបសម្ព័ន្ធ

តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.[illegible]

## ប្រកាស
## ស្តីពី
## ពន្ធលើមធ្យោបាយដឹកជញ្ជូន

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ ស្តីពីពន្ធលើមធ្យោបាយដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ ._**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន។

**ប្រការ២ ._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- មធ្យោបាយដឹកជញ្ជូន សំដៅដល់ មធ្យោបាយដឹកជញ្ជូនឬយានជំនិះគ្រប់ប្រភេទមានជាអាទិ៍ កប៉ាល់ សាឡង់ ទូក កាណូត អូប័រ រថយន្ត ក្បាលរថយន្តសណ្តោង រ៉ឺម៉កសណ្តោង ស៊ីមីរ៉ឺម៉កសណ្តោង ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែល។

២- ក្បាលរថយន្តសណ្តោង សំដៅដល់ រថយន្តសម្រាប់សណ្តោងស៊ីមីរ៉ឺម៉កសណ្តោង។

៣- ស៊ីមីរ៉ឺម៉កសណ្តោង សំដៅដល់ យានសម្រាប់ថ្គក់ជាប់នឹងក្បាលរថយន្តសណ្តោង។

**ប្រការ៤ ._**

ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវបានកំណត់តាមអត្រាដូចខាងក្រោម៖

១-មធ្យោបាយដឹកជញ្ជូនទូទៅ៖

| ល.រ | ប្រភេទមធ្យោបាយដឹកជញ្ជូន | កម្រិតប្រាក់ពន្ធ សម្រាប់ ១ឆ្នាំ/គ្រឿង (គិតជារៀល) |
|---|---|---|
| ក | រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្ត និងទម្ងន់ផ្ទុក (ទំនិញនិងមនុស្ស)]៖ | |
| | - ដល់ ៣តោន | ២០០ ០០០ |
| | - លើសពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| | - លើសពី ១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| | - លើសពី ២០តោន ឡើងទៅ | ២ ០០០ ០០០ |
| ខ | ក្បាលរថយន្តសណ្តោងរួម និងស៊ីមីរ៉ឺម៉កសណ្តោង៖ | ២ ០០០ ០០០ |
| គ | រ៉ឺម៉កសណ្តោងដែលមានទម្ងន់សរុប (ទម្ងន់រ៉ឺម៉កនិងទម្ងន់ផ្ទុក)៖ | |
| | - ចាប់ពី ៣តោន ដល់ ១០តោន | ៥០០ ០០០ |
| | - លើសពី១០តោន ដល់ ២០តោន | ១ ០០០ ០០០ |
| | - លើសពី ២០តោន ឡើងទៅ | ២ ០០០ ០០០ |

| | | | |
|---|---|---|---|
| ឃ | ជលយានឬជលយានយន្តផ្លូវទន្លេ៖ | | |
| | - ជលយានឬជលយានយន្តដឹកទំនិញ៖ | | |
| | | +ដល់ ៣តោន | ៥០ ០០០ |
| | | +លើសពី ៣តោន ដល់ ១០តោន | ១០០ ០០០ |
| | | +លើសពី ១០តោន ដល់ ២០តោន | ២០០ ០០០ |
| | | +លើសពី ២០តោន ឡើងទៅ | ៣០០ ០០០ |
| | - ជលយានឬជលយានយន្តដឹកអ្នកដំណើរ៖ | | |
| | | +កប៉ាល់មានបណ្តោយដល់ ២០ម៉ែត្រ | ១០០ ០០០ |
| | | +កប៉ាល់មានបណ្តោយលើសពី ២០ម៉ែត្រ ដល់ ៣០ម៉ែត្រ | ២០០ ០០០ |
| | | +កប៉ាល់មានបណ្តោយលើសពី ៣០ម៉ែត្រ ឡើងទៅ | ៣០០ ០០០ |
| | - ជលយានឬជលយានយន្តសណ្តោង៖ | | |
| | | +កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៦០ ០០០ |
| | | +កប៉ាល់មានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | ១៨០ ០០០ |
| | | +កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | ៣០០ ០០០ |
| | - ជលយានឬជលយានយន្តនេសាទ៖ | | |
| | | +កាណូតមានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៦០ ០០០ |
| | | +កាណូតមានកម្លាំងលើសពី ២០០សេះ ដល់ ២៥០សេះ | ១៨០ ០០០ |
| | | +កាណូតមានកម្លាំងលើសពី ២៥០សេះ ឡើងទៅ | ៣០០ ០០០ |
| ង | ជលយានឬជលយានយន្តផ្លូវសមុទ្រ៖ | | |
| | - ជលយានឬជលយានយន្តដឹកអ្នកដំណើរ៖ | | |
| | | +ទូកមានបណ្តោយដល់ ២០ម៉ែត្រ | ១០០ ០០០ |
| | | +ទូកមានបណ្តោយលើសពី ២០ម៉ែត្រ ឡើងទៅ | ១៥០ ០០០ |
| | - ជលយានឬជលយានយន្តដឹកទំនិញ៖ | | |
| | | +ទូកផ្ទុកទំនិញដល់ ១០០តោន | ២០០ ០០០ |
| | | +កប៉ាល់ផ្ទុកទំនិញលើសពី ១០០តោន ដល់ ១ ០០០តោន | ៣០០ ០០០ |
| | | +កប៉ាល់ផ្ទុកទំនិញលើសពី ១ ០០០តោន ដល់ ២ ០០០តោន | ៧៥០ ០០០ |
| | | +កប៉ាល់ផ្ទុកទំនិញលើសពី ២ ០០០តោន ឡើងទៅ | ១ ២០០ ០០០ |

| | | |
|---|---|---|
| | - ជលយានឬជលយានយន្តនេសាទ៖ | |
| | +ទូកមានកម្លាំងលើសពី ១៥០សេះ ឡើងទៅ | ១០០ ០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ១៥០សេះ ដល់ ២៥០សេះ | ៤០០ ០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៦០០ ០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | ១ ២០០ ០០០ |
| | - ជលយានឬជលយានយន្តសណ្តោង៖ | |
| | +កប៉ាល់មានកម្លាំងដល់ ២៥០សេះ | ២០០ ០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ២៥០សេះ ដល់ ៥០០សេះ | ៤០០ ០០០ |
| | +កប៉ាល់មានកម្លាំងលើសពី ៥០០សេះ ឡើងទៅ | ៦០០ ០០០ |
| ច | អូប័រផ្លូវទន្លេឬសមុទ្រ៖ | |
| | - មានកម្លាំងលើសពី ១៥០សេះ ដល់ ២០០សេះ | ៤០០ ០០០ |
| | - មានកម្លាំងលើសពី ២០០សេះ ឡើងទៅ | ៥០០ ០០០ |

២-មធ្យោបាយដឹកជញ្ជូនកែច្នៃ៖

| ល.រ | ប្រភេទមធ្យោបាយដឹកជញ្ជូន | កម្រិតប្រាក់ពន្ធ សម្រាប់ ១ឆ្នាំ/គ្រឿង (គិតជារៀល) |
|---|---|---|
| ក | រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៤ | ២០០ ០០០ |
| ខ | រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៨ | ៥០០ ០០០ |
| គ | រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ | ១ ០០០ ០០០ |
| ឃ | រថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ | ២ ០០០ ០០០ |

៣-រថយន្តទេសចរណ៍៖

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម$^{៣}$ | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | ដល់ ៥ឆ្នាំ (គិតជារៀល) | លើសពី ៥ឆ្នាំដល់ ១០ឆ្នាំ (គិតជារៀល) | លើសពី ១០ឆ្នាំ (គិតជារៀល) |
| ក | ដល់ ១ ៥០០ស.ម$^{៣}$ | ១៥០ ០០០ | ១០០ ០០០ | ៨០ ០០០ |
| ខ | លើសពី ១ ៥០០ស.ម$^{៣}$ ដល់ ២ ០០០ស.ម$^{៣}$ | ២០០ ០០០ | ១៥០ ០០០ | ១០០ ០០០ |
| គ | លើសពី ២ ០០០ស.ម$^{៣}$ ដល់ ២ ៩០០ស.ម$^{៣}$ | ៦០០ ០០០ | ៤០០ ០០០ | ២៥០ ០០០ |
| ឃ | លើសពី ២ ៩០០ស.ម$^{៣}$ ដល់ ៤ ០០០ស.ម$^{៣}$ | ១ ៦០០ ០០០ | ១ ០០០ ០០០ | ៦០០ ០០០ |
| ង | លើសពី ៤ ០០០ស.ម$^{៣}$ ឡើងទៅ | ២ ០០០ ០០០ | ១ ២០០ ០០០ | ៨០០ ០០០ |

៤- រថយន្តដឹកទំនិញធុនតូចមានទ្វារ ៤ (ភិកអាប់) ៖

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម$^{៣}$ | គិតពីឆ្នាំផលិត | |
|---|---|---|---|
| | | ដល់ ៥ឆ្នាំ (គិតជារៀល) | លើសពី ៥ឆ្នាំ (គិតជារៀល) |
| ក | ដល់ ១ ៥០០ស.ម$^{៣}$ | ១៥០ ០០០ | ១០០ ០០០ |
| ខ | លើសពី ១ ៥០០ស.ម$^{៣}$ ដល់ ២ ០០០ស.ម$^{៣}$ | ២០០ ០០០ | ១៥០ ០០០ |
| គ | លើសពី ២ ០០០ស.ម$^{៣}$ ដល់ ២ ៥០០ស.ម$^{៣}$ | ៦០០ ០០០ | ២០០ ០០០ |
| ឃ | លើសពី ២ ៥០០ស.ម$^{៣}$ ដល់ ៤ ០០០ស.ម$^{៣}$ | ១ ៦០០ ០០០ | ២០០ ០០០ |
| ង | លើសពី ៤ ០០០ស.ម$^{៣}$ ឡើងទៅ | ២ ០០០ ០០០ | ២០០ ០០០ |

៥- រថយន្តដឹកអ្នកដំណើរ៖

| ល.រ | ទំហំស៊ីឡាំងគិតជា ស.ម$^{៣}$ | គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ (គិតជារៀល) |
|---|---|---|
| ក | ដល់ ១ ៥០០ស.ម$^{៣}$ | ១៥០ ០០០ |
| ខ | លើសពី ១ ៥០០ស.ម$^{៣}$ ដល់ ២ ០០០ស.ម$^{៣}$ | ២០០ ០០០ |
| គ | លើសពី ២ ០០០ស.ម$^{៣}$ ដល់ ២ ៥០០ស.ម$^{៣}$ | ៦០០ ០០០ |
| ឃ | លើសពី ២ ៥០០ស.ម$^{៣}$ ដល់ ៤ ០០០ស.ម$^{៣}$ | ១ ៦០០ ០០០ |
| ង | លើសពី ៤ ០០០ស.ម$^{៣}$ ឡើងទៅ | ២ ០០០ ០០០ |
| | **ចំនួនកៅអី** | **គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ** (គិតជារៀល) |
| ច | រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥កៅអី | ១៥០ ០០០ |
| ឆ | រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦កៅអី ដល់ ២៥កៅអី | ២០០ ០០០ |
| ជ | រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥កៅអី ឡើងទៅ | ២៥០ ០០០ |

៦- រថយន្តប្រើប្រាស់ថាមពលអគ្គិសនី (អ៊ីវី) ប្រភេទទេសចរណ៍ រថយន្តដឹកទំនិញធុនតូចមានទ្វារ ៤ (ភិកអាប់) និងរថយន្តដឹកអ្នកដំណើរ៖

| ល.រ | គិតជាកម្លាំងសេះ | គិតពីឆ្នាំផលិត | | |
|---|---|---|---|---|
| | | ដល់ ៥ឆ្នាំ (គិតជារៀល) | លើសពី ៥ឆ្នាំដល់ ១០ឆ្នាំ (គិតជារៀល) | លើសពី ១០ឆ្នាំ (គិតជារៀល) |
| ក | ដល់ ១៥០សេះ | ១០០ ០០០ | ៨០ ០០០ | ៦០ ០០០ |
| ខ | លើសពី ១៥០សេះ ដល់ ២០០សេះ | ១៥០ ០០០ | ១០០ ០០០ | ៨០ ០០០ |
| គ | លើសពី ២០០សេះ ដល់ ២៥០សេះ | ៥០០ ០០០ | ៣០០ ០០០ | ១៥០ ០០០ |
| ឃ | លើសពី ២៥០សេះ ដល់ ៣០០សេះ | ១ ២០០ ០០០ | ៨០០ ០០០ | ៤០០ ០០០ |
| ង | លើសពី ៣០០សេះ ឡើងទៅ | ១ ៦០០ ០០០ | ១ ០០០ ០០០ | ៦០០ ០០០ |

**ប្រការ៥ .-**

ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវបានលើកលែងដូចខាងក្រោម៖

១- រថយន្តគិលានសង្គ្រោះ និងរថយន្តពន្លត់អគ្គីភ័យជាកម្មសិទ្ធិរបស់រដ្ឋ។

២- យានយន្តដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបម្រើការងារសម្រាប់គោលដៅនៃការការពារជាតិ សន្តិសុខនិងសណ្តាប់ធ្នាប់សង្គមតែប៉ុណ្ណោះ។

៣- យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូតឬស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

៤- ទោចក្រយានយន្តនិងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រនិងគ្រឿងយន្តប្រហាក់ប្រហែល និងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ (មួយរយហាសិប) សេះ ឬតិចជាង។

៥- រថយន្តដែលបំប្លែងមកពីគោយន្ត និងរថយន្តកែច្នៃកង់បីដែលបំពាក់ម៉ាស៊ីន។

**ប្រការ៦ .-**

១- ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវអនុវត្តចំពោះម្ចាស់កម្មសិទ្ធិនៃមធ្យោបាយដឹកជញ្ជូន។

២- ម្ចាស់កម្មសិទ្ធិឬអ្នកតំណាង ត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនក្នុងអំឡុងពេលចាប់ពីថ្ងៃទី១ ខែមិថុនា រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំ។

៣- ម្ចាស់កម្មសិទ្ធិឬអ្នកតំណាង ត្រូវបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូននៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត ខណ្ឌ ឬធនាគារជាដៃគូ ឬតាមរយៈកម្មវិធីទូរស័ព្ទដៃ។

**ប្រការ៧ .-**

ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន ត្រូវអនុវត្តដូចខាងក្រោម៖

១- ម្ចាស់កម្មសិទ្ធិឬអ្នកតំណាង ត្រូវមកចុះបញ្ជីនិងដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធលើកដំបូង ដោយត្រូវបំពេញព័ត៌មានទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ និងត្រូវមានឯកសារ ដូចខាងក្រោម៖

ក- រថយន្តទេសចរណ៍៖

- ច្បាប់ដើមនៃបណ្ណសម្គាល់យានជំនិះ និង
- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតឆ្លងដែនរបស់ម្ចាស់កម្មសិទ្ធិ និង
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារចំពោះនីតិបុគ្គល។

ខ- រថយន្តដឹកទំនិញ ឬរថយន្តដឹកអ្នកដំណើរ ឬជលយានយន្ត៖

- ច្បាប់ដើមនៃបណ្ណសម្គាល់យានជំនិះ និង
- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតឆ្លងដែនរបស់ម្ចាស់កម្មសិទ្ធិ និង
- ច្បាប់ដើមនៃវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ ដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន និង
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារចំពោះនីតិបុគ្គល។

គ- យានយន្តកែច្នៃក្នុងស្រុក៖

- អត្តសញ្ញាណប័ណ្ណសម្គាល់ខ្លួន ឬលិខិតឆ្លងដែនរបស់ម្ចាស់កម្មសិទ្ធិ និង
- ច្បាប់ដើមនៃលិខិតបញ្ជាក់ការប្រើប្រាស់យានជំនិះចេញដោយឃុំ សង្កាត់ និង
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារចំពោះនីតិបុគ្គល។

២- ម្ចាស់កម្មសិទ្ធិឬអ្នកតំណាង ដែលបានចុះបញ្ជីនិងប្រកាសនិងបង់ប្រាក់ពន្ធរួចម្តងមកហើយ ត្រូវមានឯកសារដូចខាងក្រោម៖

ក- បណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន ឬ

ខ- បណ្ណសម្គាល់យានជំនិះ ឬ

គ- បង្កាន់ដៃទទួលប្រាក់ពន្ធមធ្យោបាយដឹកជញ្ជូន ឬ

ឃ-លតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូនឆ្នាំចាស់។

៣- ចំពោះមធ្យោបាយដឹកជញ្ជូនដែលបានចុះបញ្ជីនិងបានដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធរួចហើយ ហើយត្រូវបានប្តូរបណ្ណសម្គាល់យានជំនិះដោយសារមានការផ្លាស់ប្តូរព័ត៌មាន ម្ចាស់មធ្យោបាយដឹកជញ្ជូនត្រូវស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មានមធ្យោបាយដឹកជញ្ជូននោះនៅអគ្គនាយកដ្ឋានពន្ធដារ ឬនៅសាខាពន្ធដារខេត្ត ខណ្ឌដើម្បីប្រកាសបង់ពន្ធបន្តព្រមទាំងអាចប្តូរបណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូនផងដែរ។

៤- ក្រោយពេលបង់ពន្ធរួច ម្ចាស់មធ្យោបាយដឹកជញ្ជូនត្រូវទទួលបានបង្កាន់ដៃទទួលប្រាក់ពន្ធមធ្យោបាយដឹកជញ្ជូននិងលតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូន។ លតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូន ត្រូវបិទភ្ជាប់ជាមួយនឹងមធ្យោបាយដឹកជញ្ជូននោះ ហើយបង្កាន់ដៃទទួលប្រាក់ពន្ធ អាចរក្សាទុកសម្រាប់ប្រើប្រាស់តាមការចាំបាច់។

៥- ម្ចាស់មធ្យោបាយដឹកជញ្ជូន អាចស្នើសុំបណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន និងបង់ថ្លៃសេវាចំនួន ៥ ០០០ រៀល នៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត ខណ្ឌ ឬនៅធនាគារដៃគូ។ បណ្ណសម្គាល់ការបង់ពន្ធមធ្យោបាយដឹកជញ្ជូន មានទម្រង់ជាបណ្ណរឹង និងបណ្ណទម្រង់ឌីជីថល (E-CARD)។ បន្ទាប់ពីការបង់ប្រាក់ពន្ធនិងថ្លៃសេវា ម្ចាស់មធ្យោបាយដឹកជញ្ជូននឹងទទួលបានភ្លាមៗនូវបណ្ណរឹង ពីអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត ខណ្ឌ ឬបណ្ណទម្រង់ឌីជីថល (E-CARD) តាមអនឡាញ។

៦- ករណីបាត់លតាបត្រ ម្ចាស់មធ្យោបាយដឹកជញ្ជូនអាចដាក់ពាក្យស្នើសុំលិខិតបញ្ជាក់ការបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន នៅអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត ខណ្ឌ ដើម្បីប្រើប្រាស់តាមការចាំបាច់។

**ប្រការ៨ .-**

ចំពោះមធ្យោបាយដឹកជញ្ជូនដែលជាកម្មសិទ្ធិរបស់ក្រសួង ស្ថាប័នរដ្ឋ ស្ថានទូត ស្ថានកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ត្រូវបានកំណត់ដូចខាងក្រោម៖

១- មធ្យោបាយដឹកជញ្ជូនដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃប្រការ៥ នៃប្រកាសនេះ ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារ ដើម្បីទទួលបាននូវលតាបត្របង់ពន្ធមធ្យោបាយដឹកជញ្ជូន (លើកលែងពន្ធ) ដោយភ្ជាប់មកជាមួយនូវបញ្ជីសារពើភណ្ឌយានយន្តទ្រព្យសម្បត្តិរដ្ឋ (តារាងកើនឡើងនិងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ) ដែលចុះបញ្ជីនៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

២- មធ្យោបាយដឹកជញ្ជូនដែលជាកម្មសិទ្ធិរបស់ក្រសួង ស្ថាប័នរដ្ឋ (ពាក់ផ្លាកលេខរដ្ឋ) ត្រូវស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារឬសាខាពន្ធដារខេត្ត ខណ្ឌ ដើម្បីបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន ដោយភ្ជាប់មកជាមួយនូវលិខិតជូនដំណឹងឥណទានរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារខេត្ត និងបញ្ជីសារពើភណ្ឌយានយន្តទ្រព្យសម្បត្តិរដ្ឋ (តារាងកើនឡើងនិងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ) ដែលចុះបញ្ជីនៅអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៩ .-**

ចំពោះមធ្យោបាយដឹកជញ្ជូនទាំងឡាយណា ដែលមានបង្កាន់ដៃបង់ពន្ធនាំចូលចេញមុនខែធ្នូ តែមានបណ្ណសម្គាល់យានជំនិះចេញលើកដំបូងក្នុងខែធ្នូនៃឆ្នាំជាប់ពន្ធចរន្ត ត្រូវបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនក្នុងឆ្នាំនោះ ដោយទទួលបានការលើកលែងប្រាក់ពន្ធបន្ថែម។ ក្នុងករណីបណ្ណសម្គាល់យានជំនិះចេញលើកដំបូងក្នុងខែធ្នូ និងមានបង្កាន់ដៃបង់ពន្ធនាំចូលចេញក្នុងខែធ្នូឆ្នាំតែមួយ ត្រូវបានអនុញ្ញាតឱ្យបង់ពន្ធសម្រាប់ឆ្នាំបន្ទាប់។

**ប្រការ១០ .-**

ជារៀងរាល់ឆ្នាំ ចាប់ពីថ្ងៃទី១ ខែមករា នៃឆ្នាំបន្ទាប់ អគ្គនាយកដ្ឋានពន្ធដារត្រូវរៀបចំយន្តការត្រួតពិនិត្យការបង់ពន្ធ និងពន្ធបន្ថែមចំពោះមធ្យោបាយដឹកជញ្ជូនដែលមិនបានដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធប្រចាំឆ្នាំ តាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ។

**ប្រការ១១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ .-**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថាន វ៉ាន់ដា

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

## ជំនាញ គណនេយ្យ

## ប្រធានបទ៖ ដំណើរការនៃការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន របស់អគ្គនាយកដ្ឋានពន្ធដារ

## TOPIC: THE PROCESS OF COLLECTING TAX ON GENERAL DEPARMENT OF TAXATION OF TRANSPORTATION


រៀបរៀងដោយនិស្សិត៖ ១-និស្សិត ពួយ សុលីនដា B20/1872

២-និស្សិត ម៉ៅ ស៊ីម៉ាច B20/755

៣-និស្សិត សុខន ស្រីពៅ B20/754

៤-និស្សិត ហាក់ ណារីន B20/737

៥-និស្សិត ម៉ា គីមលីហ្វា B20/748

អ្នកស្រី វ៉ាន់ ស្រីនាង



016.252
មេក្រុម ពួយ សុលីនដា
VIA.PP/2023


និស្សិតជំនាន់ទី២០

Scanned with CamScanner

PHNOM PENH-2023

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ថវិកាសង្ខេបឆ្នាំ ២០២២

# BUDGET IN BRIEF FISCAL YEAR 2022

នាយកដ្ឋានថវិកានីយកម្ម
អគ្គនាយកដ្ឋានថវិកា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ថវិកាសង្ខេប ឆ្នាំ ២០២៣

# BUDGET IN BRIEF

## Fiscal Year 2023

នាយកដ្ឋានថវិកានីយកម្ម

អគ្គនាយកដ្ឋានថវិកា



# ច្បាប់
# ស្តីពី
# ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២២

## តារាង "ក២"

## ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២១ | ឆ្នាំ២០២២ | ទឹកប្រាក់ | ភាគរយ |
| **សរុបរួមចំណូលថវិការាជធានី ខេត្ត (I+II)** | | | | 2,203,579.0 | 2,859,652.0 | 656,073.0 | 29.8% |
| **I. សរុបចំណូលឆ្លងកាត់តាមធនាគារជាតិ (ក+ខ)** | | | | 2,203,579.0 | 2,859,652.0 | 656,073.0 | 29.8% |
| **ក្នុងនោះចំណូលក្នុងប្រទេស** | | | | 2,203,579.0 | 2,859,652.0 | 656,073.0 | 29.8% |
| **ក. សរុបចំណូលចរន្ត (ក្រ១+ក្រ២)** | | | | 2,203,579.0 | 2,859,652.0 | 656,073.0 | 29.8% |
| **ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២)** | | | | 2,203,579.0 | 2,859,652.0 | 656,073.0 | 29.8% |
| **ប្រភេទទី១: ចំណូលសារពើពន្ធ** | | | | 1,050,323.0 | 1,584,127.0 | 533,804.0 | 50.8% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 1,050,323.0 | 1,584,127.0 | 533,804.0 | 50.8% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 154,784.5 | 281,757.2 | 126,972.7 | 82.0% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | 154,784.5 | 281,757.2 | 126,972.7 | 82.0% |
| | 7003 | | អាករពិសេស | 116,799.1 | 161,859.2 | 45,060.1 | 38.6% |
| | | 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | 116,799.1 | 161,859.2 | 45,060.1 | 38.6% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 4,998.0 | 2,872.9 | -2,125.1 | -42.5% |
| | | 70045 | អាករលើការស្នាក់នៅ | 4,998.0 | 2,872.9 | -2,125.1 | -42.5% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ ការអនុវត្តសកម្មភាព | 256,238.5 | 399,321.0 | 143,082.5 | 55.8% |
| | | 70053 | ពន្ធប៉ាតង់ | 34,999.5 | 74,795.0 | 39,795.5 | 113.7% |
| | | 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | 221,239.0 | 324,526.0 | 103,287.0 | 46.7% |
| | 7006 | | ពន្ធប្រថាប់ត្រា | 406,726.9 | 574,291.8 | 167,564.9 | 41.2% |
| | | 70061 | ពន្ធប្រថាប់ត្រា លើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ | 398,973.0 | 560,512.0 | 161,539.0 | 40.5% |
| | | 70062 | ពន្ធប្រថាប់ត្រា លើតម្លៃមធ្យោបាយដឹកជញ្ជូន ឬ យានយន្តចំពោះការផ្ទេរកម្មសិទ្ធិ | 4,485.2 | 5,770.3 | 1,285.1 | 28.7% |
| | | 70063 | ពន្ធប្រថាប់ត្រា លើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន | 1,079.0 | 3,558.2 | 2,479.2 | 229.8% |
| | | 70064 | ពន្ធប្រថាប់ត្រា លើតម្លៃកិច្ចសន្យាចំពោះការផ្គត់ផ្គង់ទំនិញ ឬ សេវា | 1,214.3 | 3,520.5 | 2,306.2 | 189.9% |
| | | 70065 | ពន្ធប្រថាប់ត្រា លើលិខិតមានលក្ខណៈគតិយុត្ត | 975.4 | 930.8 | -44.6 | -4.6% |
| | 7007 | | ពន្ធលើអចលនទ្រព្យ | 102,153.0 | 143,123.4 | 40,970.4 | 40.1% |
| | | 70071 | ពន្ធលើអចលនទ្រព្យ (រូបវន្តបុគ្គល) | 92,929.0 | 112,935.0 | 20,006.0 | 21.5% |
| | | 70072 | ពន្ធលើអចលនទ្រព្យ (នីតិបុគ្គល) | 5,130.0 | 16,494.0 | 11,364.0 | 221.5% |
| | | 70073 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 4,094.0 | 13,694.4 | 9,600.4 | 234.5% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 8,623.0 | 20,901.5 | 12,278.5 | 142.4% |
| | | 70081 | ពន្ធតែមប្រើ | 8,623.0 | 20,901.5 | 12,278.5 | 142.4% |
| **ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ** | | | | 1,153,256.0 | 1,275,525.0 | 122,269.0 | 10.6% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 14,082.6 | 37,369.8 | 23,287.2 | 165.4% |
| | 7200 | | ផលសម្បទាន | 14,082.6 | 37,369.8 | 23,287.2 | 165.4% |
| | | 72001 | ផលពីនេសាទ | 1,079.0 | 1,196.2 | 117.2 | 10.9% |
| | | 72004 | [illegible]រ៉ែ | 10,850.2 | 33,948.7 | 23,098.5 | 212.9% |
| | | | ចំណ[illegible]នជំនិះ | 1,768.5 | 1,852.5 | 84.0 | 4.7% |
| | | | ចំណ[illegible]យាន | 375.4 | 362.9 | -12.5 | -3.3% |
| | | | ផល[illegible]ានផ្សេងៗ | 9.5 | 9.5 | 0.0 | 0.0% |



Scan QR Code

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់ការ
# គ្រប់គ្រងឆ្នាំ២០២៣

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ការគ្រប់គ្រងឆ្នាំ២០២៣

## តារាង "ក២"

## ចំណូលថវិការដ្ឋបាលរាជធានី ខេត្ត

ឯកតា:លានរៀល

| ជំពូក | គណនី | អនុគណនី | បរិយាយ | ច្បាប់ហិរញ្ញវត្ថុ | | ប្រៀបធៀប | |
|---|---|---|---|---|---|---|---|
| | | | | ឆ្នាំ២០២២ | ឆ្នាំ២០២៣ | ទឹកប្រាក់ | ភាគរយ |
| សរុបរួមចំណូលថវិការាជធានី ខេត្ត (I) | | | | 2.859.652,0 | 3.436.250,0 | 576.598,0 | 20,2% |
| I. សរុបចំណូលឆ្លងកាត់តេនាគារជាតិ (ក) | | | | 2.859.652,0 | 3.436.250,0 | 576.598,0 | 20,2% |
| ក្នុងនោះចំណូលក្នុងប្រទេស | | | | 2.859.652,0 | 3.436.250,0 | 576.598,0 | 20,2% |
| ក. សរុបចំណូលចរន្ត (ក្រ១) | | | | 2.859.652,0 | 3.436.250,0 | 576.598,0 | 20,2% |
| ក្រុមទី១: ចំណូលពិត (ប្រភេទទី១+ប្រភេទទី២) | | | | 2.859.652,0 | 3.436.250,0 | 576.598,0 | 20,2% |
| ប្រភេទទី១: ចំណូលសារពើពន្ធ | | | | 1.584.127,0 | 2.172.350,0 | 588.223,0 | 37,1% |
| 70 | | | ចំណូលសារពើពន្ធក្នុងស្រុក | 1.584.127,0 | 2.172.350,0 | 588.223,0 | 37,1% |
| | 7001 | | ពន្ធផ្ទាល់ (ពន្ធលើផលទុន ប្រាក់ចំណូល) | 281.757,2 | 350.390,0 | 68.632,8 | 24,4% |
| | | 70014 | ពន្ធលើឈ្នួលចលននិងអចលនទ្រព្យ (រូបវន្តបុគ្គល) | 281.757,2 | 350.390,0 | 68.632,8 | 24,4% |
| | 7003 | | អាករពិសេស | 161.859,2 | 237.820,8 | 75.961,6 | 46,9% |
| | | 70035 | អាករសម្រាប់បំភ្លឺសាធារណៈ | 161.859,2 | 237.820,8 | 75.961,6 | 46,9% |
| | 7004 | | អាករលើសេវាដែលបានកំណត់ | 2.872,9 | 11.880,5 | 9.007,6 | 313,5% |
| | | 70045 | អាករលើការស្នាក់នៅ | 2.872,9 | 11.880,5 | 9.007,6 | 313,5% |
| | 7005 | | អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬ ការអនុវត្តសកម្មភាព | 399.321,0 | 495.712,0 | 96.391,0 | 24,1% |
| | | 70053 | ពន្ធប៉ាតង់ | 74.795,0 | 83.221,0 | 8.426,0 | 11,3% |
| | | 70054 | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ | 324.526,0 | 412.491,0 | 87.965,0 | 27,1% |
| | 7006 | | ពន្ធប្រថាប់ត្រា | 574.291,8 | 882.091,1 | 307.799,3 | 53,6% |
| | | 70061 | ពន្ធប្រថាប់ត្រា លើតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ | 560.512,0 | 852.904,4 | 292.392,4 | 52,2% |
| | | 70062 | ពន្ធប្រថាប់ត្រា លើតម្លៃមធ្យោបាយដឹកជញ្ជូន ឬ យានយន្តចំពោះការផ្ទេរកម្មសិទ្ធិ | 5.770,3 | 15.133,2 | 9.362,9 | 162,3% |
| | | 70063 | ពន្ធប្រថាប់ត្រា លើតម្លៃភាគហ៊ុនចំពោះការផ្ទេរភាគហ៊ុន | 3.558,2 | 5.106,0 | 1.547,8 | 43,5% |
| | | 70064 | ពន្ធប្រថាប់ត្រា លើតម្លៃកិច្ចសន្យាចំពោះការផ្គត់ផ្គង់ទំនិញ ឬ សេវា | 3.520,5 | 7.757,4 | 4.236,9 | 120,3% |
| | | 70065 | ពន្ធប្រថាប់ត្រា លើលិខិតមានលក្ខណៈគតិយុត្ត | 930,8 | 1.190,1 | 259,3 | 27,9% |
| | 7007 | | ពន្ធលើអចលនទ្រព្យ | 143.123,4 | 171.797,9 | 28.674,5 | 20,0% |
| | | 70071 | ពន្ធលើអចលនទ្រព្យ (រូបវន្តបុគ្គល) | 112.935,0 | 138.395,2 | 25.460,2 | 22,5% |
| | | 70072 | ពន្ធលើអចលនទ្រព្យ (នីតិបុគ្គល) | 16.494,0 | 15.697,5 | -796,5 | -4,8% |
| | | 70073 | ពន្ធលើដីធ្លីមិនបានប្រើប្រាស់ | 13.694,4 | 17.705,2 | 4.010,8 | 29,3% |
| | 7008 | | ចំណូលសារពើពន្ធផ្សេងៗទៀត | 20.901,5 | 22.657,7 | 1.756,2 | 8,4% |
| | | 70081 | ពន្ធតែមប្រិ៍ | 20.901,5 | 22.657,7 | 1.756,2 | 8,4% |
| ប្រភេទទី២: ចំណូលមិនមែនសារពើពន្ធ | | | | 1.275.525,0 | 1.263.900,0 | -11.625,0 | -0,9% |
| 72 | | | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 37.369,8 | 41.852,2 | 4.482,4 | 12,0% |
| | 7200 | | ផលសម្បទាន | 37.369,8 | 41.852,2 | 4.482,4 | 12,0% |
| | | 72001 | ផលពីនេសាទ | 1.196,2 | 956,3 | -239,9 | -20,1% |
| | | 72004 | សម្បទានរ៉ែ | 33.948,7 | 38.801,1 | 4.852,4 | 14,3% |
| | | 72006 | ចំណតយានជំនិះ | 1.852,5 | 1.752,8 | -99,7 | -5,4% |
| | | 72007 | ចំណតជលយាន | 362,9 | 342,0 | -20,9 | -5,8% |
| | | 72008 | ផលសម្បទានផ្សេងៗ | 9,5 | | -9,5 | -100,0% |
| | [illegible] | | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 207.374,0 | 237.517,4 | 30.143,4 | 14,5% |



# មេរៀនទី១ សញ្ញាណទូទៅនៃពន្ធដារ

## I. លក្ខណៈពិសេស នៃពន្ធដារ

ផ្តើមចេញពីពេលដែលសង្គមមនុស្ស ត្រូវបានបែងចែកជាវណ្ណៈ មានការតស៊ូវណ្ណៈ និងមានការកើតឡើងនៃរដ្ឋាភិបាល ដើម្បីគ្រប់គ្រងវេទនាសម្ព័ននៃប្រទេសមួយ រហូតមកដល់បច្ចុប្បន្ន ពន្ធដារ ត្រូវបានគេអនុវត្តច្រើនបែបយ៉ាង ហើយកាន់តែទូលំទូលាយ ។

**ពន្ធដារគឺជាអ្វី**? What is taxation?

១. ពន្ធ គឺជារូបភាពនៃការបែងចែកឡើងវិញ នូវចំណូលជាតិ ដែលរដ្ឋាភិបាលបានប្រើប្រាស់ដើម្បីប្រមូលចំណូល មួយផ្នែកពីគ្រប់សមាសសភាពសេដ្ឋកិច្ច ដូចជា ក្រុមហ៊ុន សហគ្រាស អាជីវកម្ម សិប្បកម្ម ពាណិជ្ជកម្ម...និងប្រជាពលរដ្ឋ ដើម្បីបម្រើឲ្យ តំរូវការរួមរបស់សង្គមជាតិទាំងមូល។

២. ពន្ធ គឺជារូបធាតុ នៃការប្រមូលចំណូលមួយ ដែលផ្សាភ្ជាប់ ជាមួយនិង សិទ្ធអំណាច នយោបាយរបស់រដ្ឋាភិបាល ដែលក្រិត្យច្បាប់ជាកំណត់ ។

៣. ពន្ធ គឺជាការបង់ភាគទាននូវកាតព្វកិច្ច របស់គ្រប់សមាសភាពសេដ្ឋកិច្ច ដែលរួមទាំងរូបវន្តបុគ្គល និង និតិបុគ្គល ជូនរដ្ឋាភិបាលដែលមានច្បាប់កំណត់។

ពន្ធមានលក្ខណៈបង្ខំ ហើយមិនសងឲ្យវិញផ្ទាល់ឡើយ ប៉ុន្តែនឹងអាចសងឲ្យវិញជាលក្ខណៈរូបភាពប្រយោល ទៅតាមគោលនយោបាយរដ្ឋាភិបាលប្រទេសនីមួយៗ ។ គ្រប់អង្គភាពអាជីវកម្ម ផលិតកម្ម សេវាកម្ម ដែលចំណុះឲ្យគ្រប់សមាសភាពសេដ្ឋកិច្ច ត្រូវមានកាតព្វកិច្ច និងទំនួញខុសត្រូវ ចំពោះមុខច្បាប់រដ្ឋ ក្នុងការអនុវត្តឲ្យបានគ្រប់គ្រាន់ក្នុងខ្ទង់ពន្ធទាំងឡាយដែលបានកំណត់ ។ និងមានសិទ្ធស្មើៗគ្នា ក្នុងការទទួលមកវិញនូវផលប្រយោជន៍ ពីរដ្ឋាភិបាលដែលប្រកបដោយយុត្តិធម៌ និង ត្រូវបានរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលមកវិញតាមរយៈគោលនយោបាយ ដែលមានបែងចែកក្នុងច្បាប់ ។

ពន្ធបានធ្វើឲ្យមានការផ្លាស់ប្តូរកម្មសិទ្ធនៃប្រភពចំណូលដែលបានប្រមូល ។បន្លាស់ប្តូរកម្មសិទ្ធិនៃប្រភពចំណូលនេះបានកំណត់ដោយមុខងារគ្រប់គ្រងសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ហើយបានស្តែងឡើងការឯកភាពគ្នា អំពីគោលចរិតផលប្រយោជន៍របស់រដ្ឋជាមួយ និងផលប្រយោជន៍ របស់ក្រុមហ៊ុនអាជីវកម្ម សេវាកម្ម និងប្រជាជនគ្រប់រូប។ នៅក្នុងយឿនសេដ្ឋកិច្ចទីផ្សារ ដែលមានសមាសភាពសេដ្ឋកិច្ចច្រើនគោលនយោបាយពន្ធដារត្រូវយកមកប្រើប្រាស់ជាចាំបាច់ ជាទូទៅពន្ធត្រូវបានចាត់ទុកជា ឧបករណ៍ហិរញ្ញវត្ថុមួយយ៉ាងមានប្រសិទ្ធភាព ក្នុងការគ្រប់គ្រងសេដ្ឋកិច្ចហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសជាតិ ។

## II. លក្ខខណ្ឌ សំណុមពរនៃពន្ធដារ

### ក. ចំពោះការគ្រប់គ្រង

ពន្ធដារ បានចូលរួមក្នុងការកែសំរួលយឿនសេដ្ឋកិច្ចជាតិទាំងមូល ដែលបានគ្រប់គ្រងដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ធ្វើការណែនាំឧបត្ថម្ភចំពោះគ្រប់សមាសភាពសេដ្ឋកិច្ចដោយសារ មូលហេតុនេះហើយរដ្ឋាភិបាល មានលទ្ធភាពគ្រប់គ្រាន់ និងចាំបាច់បែងចែកចំណូលមួយផ្នែក របស់បណ្តាគ្រប់សមាសភាពសេដ្ឋកិច្ច ក្នុងគោលបំណងអនុវត្តន៍នូវគោលដៅសេដ្ឋកិច្ចរបស់រដ្ឋាភិបាល ។

### ខ. ធំនាក់ធំនងរបស់ពន្ធដារ

# ក្រសួងអប់រំ យុវជន និងកីឡា

# MINISTRY OF EDUCATION YOUTH AND SPORTS

## វិទ្យាស្ថាន វ៉ាន់ដា

## VANDA INSTITUTE

## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ
## ជំនាញ គណនេយ្យ

# ប្រធានបទ៖ ដំណើរការនៃការប្រមូលពន្ធលើប្រាក់ចំណូលរបស់អគ្គនាយកដ្ឋានពន្ធដារ

# TOPIC: THE PROCESS OF COLLECTING INCOME TAX TO THE GENERAL DEPARTMENT OF TAXATION


| | | |
|---|---|---|
| រៀបរៀងដោយនិស្សិត៖ | ១-និស្សិត ហួរ ចន្ទា | B21/881 |
| | ២-និស្សិត គង់ គីមលី | B21/930 |
| | ៣-និស្សិត ប៊ុន ដានី | B21/1125 |
| | ៤-និស្សិត ឌី លីហ្សា | B21/2226 |
| | ៥-និស្សិត ឌី ស៊ុណា | B21/834 |

សាស្ត្រាចារ្យណែនាំ៖ ជន កល្យាណ


**និស្សិតជំនាន់ទី២១**

រាជធានីភ្នំពេញ

ឆ្នាំ២០២៤

VIA.PP/2024

Scanned with CamScanner

ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថាន វ៉ាន់ដា

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

## ជំនាញ គណនេយ្យ

# ប្រធានបទ៖ ដំណើរការនៃការបង់ពន្ធលើប្រាក់បៀវត្សជូន អគ្គនាយកដ្ឋានពន្ធដារ

# TOPIC: THE PROCESS OF PAYING SALARY TAX TO THE GENERAL DEPARTMENT OF TAXATION


រៀបរៀងដោយនិស្សិត៖ ១-និស្សិត នូ មុល្លិកា B20/526

២-និស្សិត ច្រឹក ឆេងទីន B20/877

៣-និស្សិត តាយ ស៊ីវអេង B20/1488

៤-និស្សិត ប៉ូ ស៊ីវម៉ី B20/1489

៖ ជន កល្យាណ



016.297
មេក្រុម នូ មុល្លិកា
VIA.PP/2023


និស្សិតជំនាន់ទី២០


រាជធានីភ្នំពេញ - ឆ្នាំ២០២៣

PHNOM PENH-2023

## ក. តើពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទជាអ្វី?

ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទគឺជាពន្ធប្រចាំឆ្នាំ។ ពន្ធនេះប្រមូលចំពោះមធ្យោបាយដឹកជញ្ជូន និងយាន ជំនិះគ្រប់ ប្រភេទ ដូចជារថយន្តទេសចរណ៍ រថយន្តដឹកទំនិញ រថយន្តដឹកអ្នកដំណើរ រ៉ឺម៉កសណ្តោង ជលយាន ឬជលយានយន្ត( លើសពី១៥០ សេះ ) ទាំងផ្លូវទន្លេ និងសមុទ្រ។



## ខ. និយមន័យពាក្យគន្លឹះ

- **មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ** សំដៅដល់ កប៉ាល់ សាឡង់ ទូក កាណូត អូប៊័រ រថយន្ត ក្បាលរថយន្តសណ្តោង រ៉ឺម៉កសណ្តោង ស៊ីមីរ៉ឺម៉កសណ្តោង ទោចក្រយានយន្ត ត្រីចក្រយានយន្ត ត្រាក់ទ័រនិងគ្រឿងយន្តប្រហាក់ប្រហែល។
- **អ្នកជាប់ពន្ធ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលជាកម្មសិទ្ធិករ ឬ អ្នកកាន់កាប់មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ។

## គ. ការលើកលែងពន្ធ

ពន្ធលើមធ្យោបាយដឹកជញ្ជូនយានជំនិះគ្រប់ប្រភេទត្រូវបានលើកលែងចំពោះ៖

១. រថយន្តគិលានសង្គ្រោះ និងរថយន្តពន្លត់អគ្គិភ័យដែលជាកម្មសិទ្ធិរបស់រដ្ឋ

២. យានយន្តដែលជាកម្មសិទ្ធិរបស់អង្គភាពកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិដែលបានចុះបញ្ជីសារពើភណ្ឌរបស់ស្ថាប័ននោះ

៣.យានយន្តដែលជាកម្មសិទ្ធិរបស់ស្ថានទូតឬស្ថានកុងស៊ុលបរទេសអង្គការអន្តរជាតិឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា

៤.ទោចក្រយានយន្ត និងត្រីចក្រយានយន្តគ្រប់ប្រភេទ ត្រាក់ទ័រ និងគ្រឿងយន្តប្រហាក់ប្រហែលនិងជលយានយន្តគ្រប់ប្រភេទដែលមានកម្លាំងដល់ ១៥០ សេះ។

## ឃ. អត្រាពន្ធ និងការគណនាប្រាក់ពន្ធ

- **អត្រាពន្ធ**លើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទត្រូវកំណត់ទៅតាមប្រភេទមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទដូចខាងក្រោម៖
  - ក. រថយន្តទេសចរណ៍ (គិតតាមឆ្នាំផលិត និងទំហំស៊ីឡាំង)
  - ខ. រថយន្តដឹកទំនិញ (គិតតាមទម្ងន់សរុប)
  - គ. រ៉ឺម៉កសណ្តោង (គិតតាមទម្ងន់សរុប)
  - ឃ. ក្បាលរថយន្តសណ្តោង និងស៊ីមីរ៉ឺម៉កសណ្តោង (ត្រូវបង់ពន្ធរួមគ្នាគិតតាមទម្ងន់សរុប)
  - ង. រថយន្តដឹកអ្នកដំណើរ (គិតតាមចំនួនកៅអី)
  - ច. ជលយាន ឬជលយានយន្ត (គិតតាមទម្ងន់ផ្ទុកសរុប ឬគិតតាមប្រវែងបណ្តោយ ឬគិតតាមកម្លាំងសេះ)
  - ឆ. យានឬយានយន្តកែច្នៃ (គិតតាមចំនួនភ្លៅ និងកង់)។
- **ការគណនាប្រាក់ពន្ធត្រូវបង់**

អ្នកជាប់ពន្ធអាចស្វែងរកតាមប្រកាសលេខ៥៣១សហវ.ប្រករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាចប្រើប្រាស់កម្មវិធីទូរស័ព្ទ Cambodia Road Tax (ទាំងប្រព័ន្ធប្រតិបត្តិការ Android និង iOS) ដើម្បីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ។

លោកអ្នកអាចទាញយកកម្មវិធីតាមទូរស័ព្ទដៃដូចខាងក្រោម



## ឃ. អត្រាពន្ធ និងការគណនាប្រាក់ពន្ធ (ត)

**ឧទាហរណ៍៖** រថយន្តទេសចរណ៍

ក. រថយន្តប្រភេទទេសចរណ៍ ផ្លាកលេខ ភ្នំពេញ 2T-1111 ម៉ាក LEXUS RX 350 មានទំហំស៊ីឡាំង 3500 CC ឆ្នាំផលិត ២០០៧

ខ. រថយន្តប្រភេទទេសចរណ៍ ផ្លាកលេខ ភ្នំពេញ 2AA-2222 ម៉ាក LEXUS RX 350 មានទំហំស៊ីឡាំង 3500 CC ឆ្នាំផលិត ២០១៥

តើរថយន្តនីមួយៗខាងលើត្រូវបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២១ ចំនួនប៉ុន្មានរៀល?

**ចម្លើយ៖** ផ្អែកតាមតារាងឧបសម្ព័ន្ធ II នៃប្រកាសលេខ ៥៣១ សហវ.ប្រក បានកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវបង់សម្រាប់ឆ្នាំ២០២១ ដូចខាងក្រោម៖

ក. រថយន្តផ្លាកលេខ ភ្នំពេញ 2T-1111 ឆ្នាំផលិត ២០០៧ ជារថយន្តដែលគិតពីឆ្នាំផលិតលើសពី ១០ ឆ្នាំ ប្រាក់ពន្ធត្រូវបង់ចំនួន ៦០០ ០០០ រៀល

ខ. រថយន្តផ្លាកលេខ ភ្នំពេញ 2AA-2222 ឆ្នាំផលិត ២០១៥ ជារថយន្តដែលគិតពី ឆ្នាំផលិតលើសពី ៥ឆ្នាំ ដល់ ១០ ឆ្នាំ ប្រាក់ពន្ធត្រូវបង់ចំនួន ១ ០០០ ០០០ រៀល

**ឧទាហរណ៍៖** រថយន្តដឹកទំនិញ

ក. រថយន្តដឹកទំនិញ មានផ្លាកលេខ ភ្នំពេញ 3A-4444 ម៉ាក HYUNDAI មាន ទម្ងន់ផ្ទុកសរុប ( ទម្ងន់សុប = ទម្ងន់រថយន្ត + ទម្ងន់ផ្ទុក និងមនុស្ស ) ១៥ តោន

ខ. រថយន្តដឹកទំនិញ មានផ្លាកលេខ ភ្នំពេញ 3B-5555 ម៉ាក HINO មាន ទម្ងន់ ផ្ទុកសរុប ( ទម្ងន់សុប = ទម្ងន់រថយន្ត + ទម្ងន់ផ្ទុក និងមនុស្ស ) ២៥ តោន

តើរថយន្តនីមួយៗខាងលើត្រូវបង់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២១ ចំនួនប៉ុន្មានរៀល?

**ចម្លើយ៖** ផ្អែកតាមតារាងឧបសម្ព័ន្ធ I នៃប្រកាសលេខ ៥៣១ សហវ.ប្រក បានកំណត់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនត្រូវបង់សម្រាប់ឆ្នាំ២០២១ ដូចខាងក្រោម៖

ក. រថយន្តផ្លាកលេខ ភ្នំពេញ 3A-4444 ម៉ាក HYUNDAI មានទម្ងន់ផ្ទុកសរុប ១៥ តោន ប្រាក់ពន្ធត្រូវបង់ចំនួន ១ ០០០ ០០០ រៀល

ខ. រថយន្តផ្លាកលេខ ភ្នំពេញ 3B-5555 ម៉ាក HINO មានទម្ងន់ផ្ទុកសរុប ២៥ តោន ប្រាក់ពន្ធត្រូវបង់ចំនួន ២ ០០០ ០០០ រៀល

## ខ.កាតព្វកិច្ច និងបែបបទនៃការប្រកាសបង់ពន្ធ

ពន្ធនេះជាប្រភេទពន្ធស្វ័យប្រកាសដែលតម្រូវឱ្យកម្មសិទ្ធិករមកចុះបញ្ជីយានយន្តសម្រាប់ការបង់ពន្ធនៅអគ្គនាយកដ្ឋានពន្ធដារ ឬនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅធនាគារដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ។

ចំពោះការធ្វើបច្ចុប្បន្នភាពយានយន្តកម្មសិទ្ធិករត្រូវដាក់លិខិតនិងបំពេញពាក្យសុំធ្វើបច្ចុប្បន្នភាពព័ត៌មានយានយន្ត រួចដាក់នៅអគ្គនាយកដ្ឋានពន្ធដារ ឬនៅសាខាពន្ធដារខេត្ត-ខណ្ឌ។

កម្មសិទ្ធិករត្រូវបង់ពន្ធ **យ៉ាងយឺតបំផុតត្រឹមថ្ងៃ៣០ ខែវិច្ឆិកា នៃឆ្នាំជាប់ពន្ធនីមួយៗ** នៅអគ្គនាយកដ្ឋានពន្ធដារ ឬតាមរយៈកម្មវិធី Taxpayer App ដែលមានក្នុង App Store និង Play Store។

Play Store

App Store

## ធនាគារជាដៃគូរបស់អគ្គនាយកដ្ឋានពន្ធដារ

### ទីតាំងដែលលោកអ្នកអាចអញ្ជើញទៅបង់ពន្ធបាន



## ខ.កាតព្វកិច្ច និងបែបបទនៃការប្រកាសបង់ពន្ធ (ត)

**តើការចុះបញ្ជីឬបច្ចុប្បន្នភាពព័ត៌មានយានយន្តត្រូវភ្ជាប់ឯកសារអ្វីខ្លះ ?**

**ការចុះបញ្ជីឬបច្ចុប្បន្នភាពព័ត៌មានយានយន្តត្រូវភ្ជាប់ឯកសារដូចខាងក្រោម៖**

- ប័ណ្ណសម្គាល់យានយន្ត ឬបង្កាន់ដៃបង់ពន្ធនាំចូល
- វិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានជំនិះ( សម្រាប់រថយន្តដឹកអ្នកដំណើរ និងរថយន្តដឹកទំនិញ )
- លិខិតបញ្ជាក់ការប្រើប្រាស់យានយន្តកែច្នៃក្នុងស្រុក
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ឬលិខិតបញ្ជាក់សំបុត្រកំណើត
- វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ(អាករលើតម្លៃបន្ថែម) សម្រាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទដែលជាទ្រព្យសកម្មរបស់សហគ្រាស។



**តើត្រូវធ្វើបច្ចុប្បន្នភាពព័ត៌មានយានយន្តនៅពេលណា ?**

អ្នកជាប់ពន្ធត្រូវមានកាតព្វកិច្ចធ្វើបច្ចុប្បន្នភាពព័ត៌មានយានយន្តនៅរដ្ឋបាលសារពើពន្ធក្នុងករណីមានការផ្លាស់ប្តូរដូចជា៖ ម្ចាស់កម្មសិទ្ធិ អាសយដ្ឋាន លេខទូរស័ព្ទ ផ្លាកលេខ លេខ( តួ ម៉ាស៊ីន សាក់ស៊ី ) ប្រភេទ ម៉ាក ពណ៌ កម្លាំងសេះ ឆ្នាំផលិត ទំហំស៊ីឡាំង ចំនួន( ស៊ីឡាំង ភ្លៅ កៅអី ទ្វារ កង់ ) ថ្ងៃចេញប័ណ្ណលើកដំបូង និងទម្ងន់សរុប។

**កំណត់សម្គាល់៖** ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងឡាយណាដែលមានបង្កាន់ដៃបង់ពន្ធនាំចូលចេញក្នុងខែធ្នូត្រូវបានអនុញ្ញាតឱ្យបង់ពន្ធសម្រាប់ឆ្នាំបន្ទាប់។ សម្រាប់យានយន្តដែលមានប័ណ្ណសម្គាល់យានយន្តចេញលើកដំបូងក្នុងខែធ្នូ ត្រូវបង់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទក្នុងឆ្នាំនោះដោយលើកលែងប្រាក់ពិន័យ។

**សម្រាប់ព័ត៌មានបន្ថែមលោក លោកស្រីអាចទំនាក់ទំនងតាមរយៈ**

| | |
|---|---|
| អាសយដ្ឋាន | ៖ អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី(១១០) និងម៉ៅសេទុង(២៨៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ |
| Call Center | ៖ ១២៧៧ (ដោយឥតគិតថ្លៃ) |
| គេហទំព័រ | ៖ www.tax.gov.kh |
| សារអេឡិចត្រូនិក | ៖ gdt@tax.gov.kh |

Website Facebook Instagram Youtube

បាត់ដំបង ភ្នំពេញ សៀមរាប

# វិទ្យាស្ថាន វ៉ាន់ដា
# VANDA INSTITUTE




# ច្បាប់ពន្ធដារកម្ពុជា
# Cambodia Taxation Law

រក្សាសិទ្ធិគ្រប់យ៉ាងដោយវិទ្យាស្ថាន វ៉ាន់ដា

បោះពុម្ពលើកទី១(២០២៤)

សម្រាប់ប្រើប្រាស់ផ្ទៃក្នុង